Mars-2008.qxd 3/24/2008 11:58 AM Page 1

CSC ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ០៨

## មាតិកា



យុវជនស្ម័គ្រចិត្ត ចារាំងចុះជួយសង់ផ្ទះជូនអ្នកក្រីក្រ ទំព័រ ៧



ការងារស្ម័គ្រចិត្ត ផ្តល់បទពិសោធន៍ដល់យុវជនខ្មែរ ទំព័រ ៨



របាំតោះ ត្រឡោកខ្មែរ ទំព័រ ១៤

# បន្ថិចម្តងៗ ស្ត្រីឈោងចាប់ យកឱកាសការងារក្នុងសង្គម

ទំព័រទី១០...








យានដ្ឋាន For you
for you Garage
មានទទួលជួសជុលរថយន្តគ្រប់ប្រភេទ
All Kinds of Repairing Services
សូមមេត្តាជួយផ្តល់ឱកាសដល់យុវជនក្រីក្រដែលគ្មានលទ្ធភាពទទួលការអប់រំនៅសាលា។ សូមអរគុណ!
Tell: 012 377 460 E-mail: philong2007@gmail.com
អាសយដ្ឋាន៖ ផ្លូវជាតិលេខ ៥ គីឡូម៉ែត្រលេខ ៨

កម្មវិធីវិទ្យុ



**អេម៉ាន្វែអែល** សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : **FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: **FM 102.5 Mhz** ១០:០០-១០:៣០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 100.5 Mhz** ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍

Mars-2008.qxd 3/24/2008 11:58 AM Page 2

## រូបថតសម្រាប់ខែនេះ


Photo : L. Samphors

ពិធីខួបកំណើតរបស់លោកបូជាចារ្យវ៉ង់ឌីណូ គម្រប់៨០ ចូល៨១ឆ្នាំ (ស្តាំ) និងលោកបូជាចារ្យបប់ ពិសេ គម្រប់៦៥ ចូល៦៦ឆ្នាំ (ឆ្វេង) ក្នុងថ្ងៃតែមួយនៅព្រះសហគមន៍សន្តយ៉ូសែប កាលពីថ្ងៃទី១៤ មីនា ឆ្នាំ២០០៨ ជាមួយនិងមានការចូលរួមពីបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។ **(ឆ្វេង)**

កសិករនៅប៉ៃលិនបូមទឹកបញ្ចូលស្រែ។ សព្វថ្ងៃនេះ បន្ទាប់ពីសន្តិភាពបានវិលត្រឡប់មកវិញ របរកសិកម្មនៅក្រុងប៉ៃលិនកំពុងរីកចម្រើនគួរឱ្យកត់សម្គាល់ ជំនួសឱ្យការជីករកត្បូងដែលកាន់តែខ្សត់ខ្សោយទៅដោយសារការធ្វើអាជីវកម្មយ៉ាងច្រើនលើសលប់។ **(ក្រោម)**

ជីវភាពប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិបណ្តែតទឹកនៅឃុំកំពង់ហ្លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់។ សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅតំបន់នោះគឺពឹងផ្អែកទាំងស្រុងនៅលើទឹកបឹងទន្លេសាប ដូចជាការនេសាទ ការចិញ្ចឹមត្រីក្នុងបែ ព្រមទាំងការធ្វើអាជីកម្មផ្សេងៗ លក់ដូរតាមទូក ដឹកអ្នកដំណើរ ឬធ្វើសិប្បកម្មខ្នាតតូចជាដើម។ **(ក្រោម)**


Photo : S. Philong


Photo : S. Philong

ប្រជាកសិករនៅស្រុកស្អាងកំពុងបោចស្មៅពីចំការស្លឹកខ្ទឹមរបស់គាត់។ ស្រុកស្អាង ខេត្តកណ្តាល ជាតំបន់ទំនាបជាប់នឹងដងទន្លេបាសាក់ ដែលមានដីសម្បូរជីវជាតិសម្រាប់ចំការបន្លែ។ **(ក្រោម)**


Photo : L. Sovanna

សមាគមស៊ីក្លូដឹកភ្ញៀវទេសចរទស្សនាក្រុងភ្នំពេញ កាលពីថ្ងៃ១០ ខែមីនា។ សកម្មភាពនេះផ្ញើសារដល់ប្រជាពលរដ្ឋក្នុងទីក្រុងឱ្យចូលរួមចំណែកយកចិត្តទុកដាក់អំពីបរិស្ថាន ពីព្រោះសព្វថ្ងៃនេះមានយានយន្តជាច្រើន ដែលបញ្ចេញផ្សែងបំពុលបរិយាកាស។ **(ឆ្វេង)**


Photo : S. Philong



## វិចារណកថា

# ស្ត្រី និងបុរស ជាដៃគូអភិវឌ្ឍ


Photo : L. Sovanna

**លោកអន់តូនីសាមី ស៊្វៃរាជ អភិបាលព្រះសហគមន៍កាតូលិកប្រចាំនៅភូមិភាគកំពង់ចាម**

មេភូមិជាឈ្មោះប្រធានភូមិ មានន័យថា ស្ត្រីជាប្រធានភូមិ។ ជាការពិតហើយ! បើតាមប្រពៃណីបុរាណ ប្រជាជនខ្មែរងាកទៅរកស្ត្រីជាធំ ម្តាយជាខ្លាំង និងជាមេនៅក្នុងសង្គម។ ប្រសិនយើងក្រឡេកមើលតួនាទីស្ត្រី ក្នុងការអភិវឌ្ឍន៍សង្គមខ្មែរនាពេលបច្ចុប្បន្ននេះ ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ ហួសអំពីការគិតរបស់យើងទាំងអស់គ្នា។ ស្ត្រីខ្មែររាប់ម៉ឺននាក់កំពុងតែធ្វើការតាមរោងចក្រកាត់ដេរ ដើម្បីទទួលប្រាក់ខែ ផ្គត់ផ្គង់ដល់ជីវភាពគ្រួសារនៅតាមខេត្ត។ នេះគឺជាកិត្តិយសសម្រាប់សង្គមខ្មែរទាំងមូល។ ដូច្នេះចូរយើងខំរួបរួមគ្នាកោតសរសើរនិងដឹងគុណយ៉ាងជ្រាលជ្រៅ ដល់កម្មការិនីខ្មែរ ដែលបានចូលរួមក្នុងការអភិវឌ្ឍន៍សង្គមឱ្យបានរីកចម្រើន។

ព្រះជាម្ចាស់បង្កើតមនុស្សប្រុស និងមនុស្សស្រី។ អ្នកទាំងពីរបំពេញឱ្យគ្នានូវសេចក្តីស្រលាញ់ ហើយបង្កើតនូវគ្រួសារ និងសង្គមទាំងមូល។ មនុស្សប្រុស និងស្រី មានតួនាទីផ្សេងពីគ្នា ប៉ុន្តែអ្នកទាំងពីរមានសេចក្តីថ្លៃថ្នូរ និងកិត្តិយសស្មើគ្នា។

សម្រាប់ថ្ងៃទី៨ មីនា ដែលជាថ្ងៃសិទ្ធិនារីអន្តរជាតិ គឺចង់រំឭកយើងរាល់គ្នា ឱ្យអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានរបស់ព្រះអង្គដល់យើងរាល់គ្នា ឱ្យមានអ្នកម្តាយ ភរិយា បងប្អូនស្រី និងកូនស្រី ដែលគួរឱ្យស្រលាញ់ នៅក្នុងគ្រួសារ។ ទិវានេះក៏ចង់រំឭកយើងផងដែរថា ស្ត្រីក្នុងសង្គមបច្ចុប្បន្នកំពុងប្រឈមនឹងវិបត្តិធំៗ ដែលយើងមិនត្រូវព្រងើយកន្តើយឡើយ ដោយយើងទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់ស្រលាញ់ និងចូលរួមលើកតម្កើងតម្លៃស្ត្រីឱ្យកាន់តែល្អប្រសើរឡើង។ ទោះជាស្ត្រីមានសិទ្ធិស្មើគ្នាជាមួយបុរសក៏ដោយ យើងគួរយកចិត្តទុកដាក់ពីសុវត្ថិភាពរបស់ស្ត្រីផងដែរ ដើម្បីធានាកិត្តិយសស្ត្រីជាមេគ្រួសារ និងជាអ្នកដឹកនាំសង្គម។ អតីតសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ មានប្រសាសន៍នៅក្នុងលិខិត **Familiaris consortio** (#22) ថា បើយើងទាំងអស់គ្នាចង់ឱ្យសង្គម និងវប្បធម៌មានការរីកចម្រើន យើងគួររៀបចំតួនាទី និងវិជ្ជាជីវៈរបស់ស្ត្រី ឱ្យស្មើភាពគ្នាជាមួយបុរស។

CSC

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
**Tel/Fax : (855) 23 224 120;**
**E-mail :** csccambodia@gmail.com;
**Website :** www.catholiccambodia.org;

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។
**Licence** ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៨ ថ្មី ដែលជាចម្រៀងកោតសរសើរព្រះយេស៊ូគ្រីស្ត និងយុវជនផងដែរ។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងទូរស័ព្ទ : ០១២ ២៤៤ ៧៣៨។

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត!** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មនឹងគិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។

### សារសម្រាប់មិត្តអ្នកអាន!

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី ១៦ រួចទើបមើលចម្លើយនេះ។**

ល្បែង១ : រូបក ត្រូវនឹងស្រមោលលេខ៤/ ខ-៥/គ-៣ និងឃ-១១ ហើយស្រមោលដែលនៅសល់តែឯង គឺស្រមោលលេខ ២។

**សេចក្តីជូនដំណឹង!** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយនិងចំណេញច្រើនសូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការ ក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

## ក្នុងរដូវបុណ្យចម្លង យើងនឹកសញ្ជឹងគិតអំពីព្រះយេស៊ូទទួលព្រះជន្មដ៏រុងរឿង

នៅរាត្រីបុណ្យចម្លង យើងប្រកាសជំនឿថា ព្រះជាម្ចាស់បានប្រោសលោកយេស៊ូដែលរងទុក្ខលំបាកយ៉ាងសែនអាម៉ាស់ និងវេទនា ឱ្យ "តើនឡើងពីចំណោមមនុស្សស្លាប់"។ ព្រះអង្គក៏ប្រទានឱ្យលោកបាន "ពោរពេញដោយសិរីរុងរឿង"។ ព្រះអង្គឱ្យលោកបាន "ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ"។ ព្រះអង្គ "លើកលោកឡើង" ទៅស្ថានបរមសុខ ឱ្យ "គង់ខាងស្ដាំ" ព្រះអង្គប្រទានឋានៈលោកស្មើនឹងព្រះអង្គ។ ព្រះអង្គ "តែងតាំងលោកជាព្រះគ្រីស្ដ និងជាព្រះអម្ចាស់"។ ក្នុងរយៈពេល៥០ថ្ងៃ ព្រះសហគមន៍ណែនាំគ្រីស្ដបរិស័ទឱ្យនឹកសញ្ជឹងគិតពីអត្ថន័យយ៉ាងជ្រៅនៃព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ។ នេះជាគ្រឹះនៃជំនឿរបស់យើង។ ក្នុងរដូវបុណ្យចម្លង ព្រះសហគមន៍ចាត់ចែងឱ្យគ្រីស្ដបរិស័ទអានគម្ពីរ "កិច្ចការគ្រីស្ដទូត" ដែលជា "កិច្ចការរបស់ព្រះវិញ្ញាណ" គឺព្រះយេស៊ូនៅតែបន្តសកម្មភាពក្នុងចំណោមយើងសព្វថ្ងៃ ដូចកាលពីមុនដែរ។

## ថ្ងៃអាទិត្យទី២ នៃបុណ្យចម្លង (ថ្ងៃទី៣០ មីនា ឆ្នាំ២០០៨)

(យ៉ូហាន ២០,១៩-៣១) នៅថ្ងៃព្រះយេស៊ូទទួលជ័យជម្នះលើសេចក្ដីស្លាប់ ព្រះអង្គមានព្រះជន្មថ្មីប្លែកពីមុន។ ព្រះអង្គចូលក្នុងផ្ទះក្រុមសាវ័ករស់នៅដោយមិនបាច់បើកទ្វារទេ។ ព្រះអង្គនាំសេចក្ដីសុខសាន្ដដ៏ពិតប្រាកដឱ្យគេ និងឱ្យមនុស្សលោក គឺឱ្យគេរួចផុតពីអំពើបាប។ ព្រះអង្គផ្លុំលើក្រុមសាវ័ក គឺជាការប្រទានព្រះវិញ្ញាណឱ្យគេ។ ក្រុមសាវ័កដែលភ័យខ្លាចកាលពីមុន ក៏បែរជាមានចិត្តក្លាហានហ៊ានចេញទៅប្រកាសដំណឹងល្អនេះ។ អ្នកផ្ញើជីវិតលើព្រះយេស៊ូក៏រស់នៅតាមរបៀបថ្មី គឺយកទ្រព្យសម្បត្តិរបស់ខ្លួនទៅលក់ រួចយកប្រាក់ទៅចែកចាយឱ្យដល់អ្នកក្រីក្រ។ របៀបរស់នៅថ្មីបែបនេះ គឺពិតជាសញ្ញាសម្គាល់ បញ្ជាក់តាមប្រវត្តិសាស្ដ្រថា ព្រះយេស៊ូពិតជាបានឈ្នះលើសេចក្ដីស្លាប់។ ព្រះអង្គគឺពិតជាព្រះអម្ចាស់ និងជាព្រះគ្រីស្ដមែន។ តើយើងជាគ្រីស្ដបរិស័ទនៅប្រទេសកម្ពុជារស់នៅតាមរបៀបប្លែកពីអ្នកដទៃត្រង់ណា ?

## ថ្ងៃអាទិត្យទី ៣ នៃបុណ្យចម្លង (ថ្ងៃទី០៦ មេសា ឆ្នាំ២០០៨)

(លូកា ២៤,១៣-៣៥) ព្រះយេស៊ូដែលទទួលព្រះជន្មដ៏រុងរឿង ធ្វើដំណើរជាមួយយើងសព្វថ្ងៃ ដូចកាលពីមុន ដែលព្រះអង្គធ្វើដំណើរជាមួយសាវ័កពីរនាក់ទៅភូមិអេម៉ាអ៊ូស។ យើងមិនឃើញព្រះអង្គទេ ប៉ុន្ដែព្រះអង្គគង់នៅជាមួយពិតមែន។ ជួនកាលយើងខកចិត្ត ដូចគេសង្ស័យអំពីព្រះបន្ទូលព្រះយេស៊ូ ប៉ុន្ដែព្រះអង្គលើកទឹកចិត្តយើង។ អត្ថបទនេះពន្យល់អំពីវត្តមានថ្មីរបស់ព្រះយេស៊ូ គឺព្រះអង្គគង់នៅជាមួយយើងនៅពេលយើងនឹកសញ្ជឹងគិតអំពីព្រះគម្ពីរ និងនៅពេលយើងរួម "កាច់នំប៉័ង" ថ្វាយអភិបូជាជាដើម។ ព្រះគម្ពីរជាពន្លឺ បំភ្លឺការរស់នៅរបស់យើងសព្វថ្ងៃ ជាពិសេសផ្ដល់អត្ថន័យទៅដល់ទុក្ខលំបាករបស់យើង និងរបស់មនុស្សលោក ដែលយើងថ្វាយរួមនឹងព្រះយេស៊ូដែលបានបូជាព្រះជន្ម។

## ថ្ងៃអាទិត្យទី ៤ នៃបុណ្យចម្លង (ថ្ងៃទី១៣ មេសា ឆ្នាំ២០០៨)

(យ៉ូហាន ១០,១-១០) ព្រះយេស៊ូដែលមានព្រះជន្មដ៏រុងរឿង បានណែនាំយើងជាអ្នកជឿលើព្រះអង្គដោយយកចិត្តទុកដាក់ លើព្រះហឫទ័យស្រឡាញ់ ដូចគង្វាលដែលតែងណែនាំកូនចៀមរបស់ខ្លួន។ ព្រះអង្គជាគង្វាលផង និងជាទ្វារផង ព្រះអង្គណែនាំយើងទៅកាន់ជីវិតដ៏ពេញលេញរួមជាមួយព្រះបិតា។ ព្រះអង្គចែករំលែកព្រះជន្មផ្ទាល់របស់ព្រះអង្គឱ្យអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ។

## ថ្ងៃអាទិត្យទី ៥ នៃបុណ្យចម្លង (ថ្ងៃទី២០ មេសា ឆ្នាំ២០០៨)

### "ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ជាជីវិត"

(យ៉ូហាន ១៤,១-១២) ព្រះយេស៊ូមិនគ្រាន់តែជាព្រះបរមគ្រូ ដែលបង្ហាញអំពីមាគ៌ាទៅស្ថានបរមសុខប៉ុណ្ណោះទេ។ ព្រះអង្គផ្ទាល់ថែមទាំងជាមាគ៌ានាំអ្នកជឿទៅកាន់ព្រះបិតាផងដែរ។ អ្នកផ្ញើជីវិតលើព្រះអង្គអាចឆ្លងទៅកាន់ព្រះបិតាបាន។ ព្រះយេស៊ូដែលគង់នៅជាមួយព្រះបិតា បានសម្ដែងនូវសេចក្ដីពិតអំពីព្រះបិតា និងផ្ដល់ព្រះជន្មផ្ទាល់របស់ព្រះអង្គឱ្យយើង។ តាមរយៈព្រះយេស៊ូ យើងជាបុត្រធីតារបស់ព្រះបិតាដែរ។ គ្រីស្ដសាសនាមិនមែនជាទ្រឹស្ដីដ៏ល្អទេ គឺជារបៀបរស់នៅថ្មីរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណតាំងពីពេលនេះរហូតទៅ។

## សម្រាប់កុមារ


Photos: DR

**ប្អូនៗជាទីស្រឡាញ់ !**

កាលពីលេខមុន យើងបានស្គាល់រួចហើយអំពីរដូវអប់រំពិសេសតាមប្រតិទិននៃព្រះសហគមន៍កាតូលិក។ ពេលនេះ អ្នកនាំសារសូមនាំប្អូនៗឱ្យស្គាល់ពិធីមួយទៀតដែលព្រះសហគមន៍ប្រារព្ធធ្វើក្នុងរដូវអប់រំពិសេសនេះជារៀងរាល់ឆ្នាំដែរ គឺពិធីប្រសិទ្ធពរលើប្រេង។ តើជាប្រេងអ្វី ? តើព្រះសហគមន៍យកប្រេងនេះទៅធ្វើអ្វី ?

ជាធម្មតាព្រះសហគមន៍ប្រារព្ធពិធីប្រសិទ្ធពរប្រេងនេះនៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៃរដូវអប់រំពិសេសនៅតាមភូមិភាគនីមួយៗ។ ដោយឡែកសម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា ពិធីនេះប្រារព្ធធ្វើមួយសប្ដាហ៍មុនរួមគ្នានៅភ្នំពេញ ដោយហេតុថា នៅក្នុងសប្ដាហ៍ពិសិដ្ឋ លោកអភិបាល និងលោកបូជាចារ្យទាំងអស់ជាប់រវល់រួមជាមួយបងប្អូននៅតាមព្រះសហគមន៍នានានៅក្នុងភូមិភាគទាំងបី។ នៅថ្ងៃនោះ អស់លោកបូជាចារ្យរំឭក និងប្រកាសនូវពាក្យសច្ចាជាថ្មីឡើងវិញនៅចំពោះមុខលោកអភិបាល។ ប្រេងដែលប្រសិទ្ធពរនៅក្នុងពិធីនេះ សម្រាប់យកទៅប្រើប្រាស់នៅក្នុងពិធីបុណ្យនានារយៈពេលមួយឆ្នាំ។ សហគមន៍គ្រីស្ដបរិស័ទយកប្រេងទុកជានិមិត្តរូបនៃព្រះវិញ្ញាណដែលជាព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់។ ព្រះអង្គបានជ្រួតជ្រាបក្នុងគំនិត ហើយប្រទានទាំងកម្លាំង និងអំណរសប្បាយទៅដល់អស់អ្នកជឿផងដែរ។

ប្រេងពិសិដ្ឋអស់ទាំងនេះ មានបីយ៉ាងដូចជា:

ប្រេង សម្រាប់លាបឱ្យអ្នកជំងឺ

ប្រេង សម្រាប់លាបឱ្យអ្នកដែលកំពុងរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក

ប្រេងគ្រីស្មា គឺប្រេងសម្រាប់លាបឱ្យអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក និងទទួលអគ្គសញ្ញាលាបថ្វាស ព្រមទាំងសម្រាប់លាបឱ្យលោកបូជាចារ្យដែលលោកអភិបាលទើបនឹងតែងតាំងឡើង។

ចំពោះប្រេងដែលនៅសល់ក្នុងឆ្នាំនីមួយៗ គឺគេមិនយកមកប្រើនៅឆ្នាំបន្ទាប់ទៀតទេ។ ប្រេងទាំងនេះត្រូវដុតចោលដោយត្រឹមត្រូវ មិនអាចយកទៅចាក់ចោល ឬបោះចោលនៅក្នុងធុងសំរាមនោះទេ ព្រោះនេះជា "ប្រេងពិសិដ្ឋ"។

លី សុវណ្ណា



# ព្រឹត្តិការណ៍ប្រចាំខែ



Photo: DR

## យុទ្ធនាការប្រាំខេត្តប្រឆាំងអំពើជួញដូរមនុស្សនៅមូលដ្ឋាន

យុទ្ធនាការ ២២ថ្ងៃ ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្សនៅមូលដ្ឋាន បានចាប់ផ្ដើម កាលពីថ្ងៃទី១០ មីនា នៅខេត្តស្វាយរៀង ដែលនៅទីនោះមានកុមារខ្មែរមួយចំនួន ត្រូវបានគេជួញដូរយកទៅដើរសុំទាននៅប្រទេសវៀតណាម។ យុទ្ធនាការនេះនឹងបន្តនៅ ខេត្តសៀមរាប បន្ទាយមានជ័យ ក្រុងព្រះសីហនុ ហើយដែលត្រូវបានបញ្ចប់នៅទីក្រុងភ្នំពេញ នៅដើមខែមេសានេះ។ ឯកឧត្តមស ខេង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ក្នុងពិធីបើកយុទ្ធនាការប្រឆាំងអំពើជួញដូរមនុស្សនាដើមខែមីនានេះថា: "ការប្រយុទ្ធប្រឆាំងអំពើជួញដូរគឺជាអាទិភាពរបស់រដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលបានទទួលខុសត្រូវក្នុងការដឹកនាំប្រឆាំងការជួញដូរ ពីព្រោះអំពើនេះជាការគំរាមកំហែងដោយផ្ទាល់ សម្រាប់វប្បធម៌ និងប្រពៃណីគ្រួសារខ្មែរ និងតម្លៃសង្គមកម្ពុជា។

## គ្មានភាពជាប់គាំងនយោបាយទៀតទេ ក្រោយការបោះឆ្នោតឆ្នាំ២០០៨

សម្ដេចហ៊ុន សែន បានធ្វើការប្រកាសជាសាធារណៈនៅឯពិធីបិទសន្និបាតក្រសួងមហាផ្ទៃនៅថ្ងៃ ១៣ មីនា ថា ភាពជាប់គាំងនយោបាយ នៅក្រោយពេលបោះឆ្នោត នាខែកក្កដាខាងមុខនេះ នឹងគ្មានទៀតទេ។ សុទិដ្ឋិនិយមបែបនេះ គឺបានសំដៅទៅដល់ប្រព័ន្ធបោះឆ្នោតថ្មី ៥០% បូក១ ដែលផ្ទុយពីប្រព័ន្ធសមាមាត្រ ពីរភាគបី ដើម្បីឱ្យគណបក្សដែលមានសម្លេងសភាចូលរួមបង្កើតរដ្ឋាភិបាលថ្មីបាន។ សម្ដេចហ៊ុនសែន ក៏បញ្ជាក់ថា ប្រព័ន្ធបោះឆ្នោតជាតិលើកទី៤នេះ នឹងផ្ដល់ភាពងាយស្រួលដល់គណបក្សដែលឈ្នះឆ្នោតបង្កើតរដ្ឋាភិបាល បានឆាប់រហ័សដោយបញ្ចៀសបាននូវរាល់ការតថ្លៃទាំងឡាយ ដូចកាលពីឆ្នាំ១៩៩៨ និងឆ្នាំ២០០៣។ ជាមួយគ្នានេះផងដែរ ប្រមុខរាជរដ្ឋាភិបាលបច្ចុប្បន្ន ក៏បានប្រកាសថា លោកនឹងចុះចេញពីតំណែង ប្រសិនជាគណបក្សប្រជាជនចាញ់ឆ្នោត ហើយលោកសន្យាទៀតថា លោកនឹងជួយបង្កឱ្យមានលក្ខណៈងាយស្រួល ដល់អ្នកឈ្នះឆ្នោត អាចបង្កើតរដ្ឋាភិបាលឱ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។

## មហាសេដ្ឋីរុស្ស៊ីជាប់គុក ១៣ ឆ្នាំ ពីបទអនាចារ

តុលាការក្រុងភ្នំពេញ ផ្ដន្ទាទោសដាក់គុកមហាសេដ្ឋីជនជាតិរុស្ស៊ី ដែលបានវិនិយោគ ៣០០លានដុល្លារ លើកោះពស់ក្នុងក្រុងព្រះសីហនុ ចំនួន១៣ឆ្នាំ និងអ្នកផ្សំគំនិត ជនជាតិខ្មែរ ១១ឆ្នាំ ហើយត្រូវបង់សំណងជំងឺចិត្ត ១០ម៉ឺនដុល្លារលើក្មេងស្រីរងគ្រោះ អាយុ១៤ឆ្នាំ។ សាលក្រមតុលាការក្រុងភ្នំពេញបានប្រកាសកាលពីថ្ងៃទី១៤ ខែមីនា ដោយចៅក្រមជំនុំជម្រះ កែ សាខន គឺអាឡិចសាន់ដឺ ត្រូហ្វីម៉ូវ មានអាយុ ៤១ឆ្នាំ ត្រូវបានចោទប្រកាន់អំពីបទប្រព្រឹត្តអំពីអនាចារ និងជនជាតិខ្មែរត្រូវចោទពីបទផ្សំគំនិតប្រព្រឹត្តអំពើអនាចារលើកុមារីខ្មែរ នៅទីក្រុងព្រះសីហនុ។ ជនជាប់ចោទ ទាំងពីរនាក់ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារកាលពីខែតុលាកន្លងទៅនេះ។

រស់ ឌីណា

**ភូមា** : រដ្ឋធម្មនុញ្ញថ្មីនឹងត្រូវដាក់ឱ្យប្រើប្រាស់។ សមាគមអាស៊ាន និងសហរដ្ឋអាមេរិក បានរិះគន់អនាគតរដ្ឋធម្មនុញ្ញថ្មីរបស់ក្រុមយោធាកាន់អំណាច ដែលហាមឃាត់ជនជាតិភូមាទាំងអស់ ដែលបានរៀបការជាមួយជនបរទេស មិនឱ្យឈរឈ្មោះបោះឆ្នោត។ នេះធ្វើឱ្យលោកស្រីអង់សាន ស៊ូជី មេដឹកនាំបក្សប្រឆាំង និងមានស្វាមីជាជនជាតិអង់គ្លេស មិនអាចឈរឈ្មោះឱ្យគេ បោះឆ្នោតបានផងដែរ។

**ថៃ** : លោកថាក់ស៊ីនដែលវិលត្រឡប់មកកាន់ប្រទេសថៃ ធ្លាប់បានប្រកាសច្រើនលើកច្រើនសានាប៉ុន្មានខែចុងក្រោយនេះថា: "លោកចង់ត្រឡប់មកកាន់ប្រទេសខ្លួនវិញធ្វើជាប្រជាពលរដ្ឋសាមញ្ញដើម្បីបង្ហាញអំពីភាពស្មោះត្រង់របស់លោក"។ តែអ្នកវិភាគជាច្រើនបានអះអាងថា តាមពិតលោកស្រមៃថានឹងអាចវិលមកកាន់ឆាកនយោបាយវិញ។

**វៀតណាម** : **ជាប់ពន្ធនាគារសម្រាប់ល្បែងភ្នាល់ខុសច្បាប់**

តុលាការវៀតណាមទើបនឹងធ្វើការផ្ដន្ទាទោសជាទម្ងន់ ឱ្យជាប់ក្នុងពន្ធនាគារងងឹត ទៅលើសមាជិកនៃបណ្ដាញអ្នកលេងល្បែងភ្នាល់បាល់ខុសច្បាប់នៅក្នុងប្រទេសនេះ។ ពួកគេត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋជនដោយបានរៀបចំឱ្យមានការភ្នាល់បាល់នៅក្នុងទំហំទឹកប្រាក់មិនតិចជាង ១០,៣ លានដុល្លារឡើយ សម្រាប់ការប្រកួតពានរង្វាន់បាល់ទាត់អឺរ៉ុប ហើយក្រុមពួកគេបានរៀបចំទំនាក់ទំនងជាមួយនិងបណ្ដាញនៃអ្នកភ្នាល់បាល់ដទៃៗទៀតនៅហុងកុង និងម៉ាកាវ...។

## ព្រះវិហារបាត់បង់ និង សុទិដ្ឋិនិយមទាមទារមកវិញ


Photo: PR

តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក ក្រុមអ្នកកាន់ជំនឿសាសនាកាតូលិកនៅប្រទេសវៀតណាម ដែលមានបំណងតវ៉ាទាមទារយកមកវិញនូវព្រះវិហារធំកាតូលិក បានធ្វើបាតុកម្មអហិង្សា ដោយអធិដ្ឋាននៅជិតព្រះវិហារកាតេដ្រាល់សន្ដយ៉ូសែប ជាច្រើនលើកច្រើនសានៅទីក្រុងហាណូយ។ ព្រះវិហារនេះជាគ្រឹះស្ថានរបស់គណៈប្រតិភូកាតូលិក ហើយត្រូវទាមទារយកដោយក្រុមកុំម្មុយនិស្តតាំងពីឆ្នាំ១៩៥៤។ ទោះបីបាតុកម្មតែងស្ថិតនៅក្នុងលក្ខណៈសន្តិភាព និងស្ងប់ស្ងាត់ ប៉ុន្ដែឧប្បត្តិហេតុធ្ងន់ធ្ងរនានានៅកើតមានឡើងជាមួយប៉ូលីស។ កិច្ចការចរចាដើម្បីទាមទារតែងធ្វើរហូតជាមួយនឹងរដ្ឋាភិបាល។ គ្រីស្ដបរិស័ទកំពុងមានការអត់ធ្មត់។ ប៉ុន្ដែពួកគេសន្យាថា ក្នុងករណីដែលការសន្យារបស់រដ្ឋាភិបាលដើម្បីសងវិញមិនត្រូវបានប្រកាន់យកទេនោះ ការទាមទារនឹងត្រូវធ្វើជាដរាប។ ជាក់ស្ដែងបាតុកម្មនៅអំឡុងសប្ដាហ៍ពិសិដ្ឋ ថ្ងៃព្រះយេស៊ូរងទុក្ខលំបាក គឺថ្ងៃទី១៦ ខែមីនាកន្លងទៅ។ **P.R**

Mars-2008.qxd 3/24/2008 11:59 AM Page 6



# ពង្រឹងគរុកោសល្យដល់អ្នកអប់រំបន្តជំនឿនៅកំពង់ចាម

**ឡុង សម្ផស្ស**

អំឡុងពីថ្ងៃទី០៨-១០ មីនា ឆ្នាំ២០០៨ កន្លងទៅ នៅព្រះសហគមន៍កាតូលិក នាខេត្តកំពង់ចាម មានរៀបចំនូវសិក្ខាសាលាអ្នកអប់រំបន្តជំនឿ សម្រាប់ភូមិភាគទាំងបី ក្រោមប្រធានបទ : "ការអប់រំបន្តជំនឿ និងគរុកោសល្យនៃការបង្រៀន ។" អញ្ជើញចូលរួមក្នុងឱកាសនោះ មានលោកអភិបាលភូមិ-ភាគកំពង់ចាម លោកបូជាចារ្យ បងស្រី រួមនិងបងប្អូន ដែលជាអ្នកអប់រំបន្តជំនឿ តាមព្រះសហគមន៍នានាមកពីភូមិភាគទាំងបីចំនួន ៨៥នាក់ ។

ថ្លែងនៅក្នុងពេលបើកកម្មវិធី លោកអន់តូនី សាមី អភិបាលភូមិភាគកំពង់ចាម បានមានប្រសាសន៍ថា យើងជាព្រះសហគមន៍ ។ យើងត្រូវរួបរួមគ្នាលើកតម្កើងសិរីរុងរឿង របស់ព្រះជាម្ចាស់តាមរយៈការជួយណែនាំ និងបន្តជំនឿដល់បងប្អូន ដែលកំពុងតែស្វែងរកព្រះយេស៊ូ ។

ចំណែកលោកបូជាចារ្យ ហ្វ្រង់ស័រ ប៉ុងសូរ៉ី ប្រធានមណ្ឌលវប្បធម៌កាតូលិក បានមានប្រសាសន៍ដែរថា សិក្ខាសាលានេះមានគោលបំណងដើម្បីជួយពង្រឹងសមត្ថភាពដល់បងប្អូន ដែលជាអ្នកអប់រំបន្តជំនឿ លើសពីនេះ ក៏ជួយពួកគេបន្ថែមទៀតអំពីគរុកោ-សល្យ សម្រាប់ការបង្រៀន ហើយនិងចិត្តសាស្ត្ររបស់កុមារ និងមនុស្សពេញវ័យផងដែរ ។



Photo: L. Samphors

លោកបូជាចារ្យ បងស្រី រួមនិងបងប្អូនដែលជាអ្នកអប់រំបន្តជំនឿមកពីព្រះសហគមន៍ភូមិភាគទាំងបី ចូលរួមក្នុងអង្គសិក្ខាសាលាពង្រឹងគរុកោសល្យ និងចិត្តសាស្ត្រ


## ជ្រើសរើសបុគ្គលិក

ការិយាល័យ CSC ត្រូវការជ្រើសរើសអ្នកកាសែត
ដែលមានវិជ្ជាជីវៈច្បាស់លាស់ ដែលមានជំនាញខាងសរសេរ
អំពីប្រធានបទសង្គមដើម្បីមកចូលរួមក្នុងក្រុម ។
បេក្ខជនត្រូវមានបទពិសោធន៍លើមូលដ្ឋានផ្ទាល់យ៉ាងហោចណាស់
៣ឆ្នាំ ឧស្សាហ៍រហ័សរហួន ចំណង់ចំណូលចិត្តចំពោះវិជ្ជាជីវៈខ្លួន
និងមានទំនួលខុសត្រូវខ្ពស់ ។ បេក្ខជនត្រូវចេះភាសាបារាំង ឬអង់គ្លេស
ទាំងសរសេរ និងនិយាយ ។ បេក្ខនារីត្រូវបានផ្តល់អាទិភាព ។

ការិយាល័យ CSC ត្រូវការជ្រើសរើសអ្នកកាន់កិច្ចការទីផ្សារ
ដែលមានបរិញ្ញាបត្រទីផ្សារ ។
បេក្ខជនត្រូវមានបទពិសោធន៍យ៉ាងហោចណាស់ ៣ឆ្នាំ ។
បេក្ខជនអាចធ្វើការនៅការិយាល័យ ឬចុះទៅធ្វើការនៅទីកន្លែង
ផ្សេងៗ ឧស្សាហ៍រហ័សរហួន មានចំណង់ចំណូលចិត្តចំពោះវិជ្ជាជីវៈខ្លួន
និងមានភាពម្ចាស់ការ ។ បេក្ខជនត្រូវចេះភាសាបារាំង ឬអង់គ្លេស
ទាំងសរសេរ និងនិយាយ ។ បេក្ខនារីត្រូវបានផ្តល់អាទិភាព ។

CSC ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ
៧មករា រាជធានី ភ្នំពេញ ។ Tel : (855) 23 224 120
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org;


## មរណភាពលោកស្រី Chiara Lubich ស្ថាបនិកចលនាសមាគម FOCOLARE



Photo: DR

ទីក្រុងរ៉ូម : ស្ថិតក្នុងភាពស្ងៀមស្ងាត់ សំឡេងអធិដ្ឋាន និងការរំជួលចិត្ត កើតមានឡើងពេលលោកស្រីគីអារ៉ា លូប៊ិច ទទួលមរណភាពនាយប់ថ្ងៃទី១៤ មិនា ឆ្នាំ២០០៨ វេលាម៉ោង២យប់ ក្នុងជន្មាយុ៨៨ឆ្នាំ នៅផ្ទះរបស់គាត់ក្នុងទីក្រុងរ៉ូម។ លោកស្រីគីអារ៉ា លូប៊ិច កើតនៅក្នុងទីក្រុងត្រេនតូ ឆ្នាំ១៩២០ និងបានចាប់ផ្តើមចលនាសមាគម FOCOLARE។ សព្វថ្ងៃចលនានេះមានសមាជិករាប់ពាន់នាក់ នៅ១៨២ប្រទេសនៅជុំវិញពិភពលោក ដែលរួមមានទាំងកាតូលិក និងប្រូតេស្តង់ ប្រមាណ ៣៥០និកាយផ្សេងគ្នា ព្រមទាំងសាសនាយូដា ម៉ូស្លីម ព្រះពុទ្ធ ហិណ្ឌូ ដែលប្ដេជ្ញាចិត្តរួមរស់ជាមួយគ្នាជាភាតរភាពជាមួយមនុស្សគ្រប់ជាតិសាសន៍ទូទាំងសកលលោក ដើម្បីកសាងសន្តិភាព និងឯកភាព។ សម្ដេចប៉ាបបេណឺឌីកទី១៦ បញ្ជាក់ថា : "ខ្ញុំរំជួលចិត្តជាខ្លាំងពេលបានទទួលដំណឹងពីមរណភាពរបស់លោកស្រីជាគ្រីស្តបរិស័ទពេញដោយជំនឿលើព្រះយេស៊ូ។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានលោកស្រីធ្វើជាសាក្សីរបស់ព្រះអង្គក្នុងជីវិតយើងខ្ញុំ"។

ហ្វីដេស





# យុវជនស្ម័គ្រចិត្តបារាំងចុះជួយកសាងផ្ទះ

**ហ៊ូ សុខធារី**

យុវជនមួយក្រុមមានសមាជិកចំនួន ១៣នាក់ បានចំណាយពេលវេលាវិស្សមកាលរបស់ខ្លួនមកកាន់ប្រទេសកម្ពុជាដើម្បីជួយកសាងផ្ទះជូនប្រជាជនក្រីក្រនៅក្នុងព្រះសហគមន៍កាតូលិក ភូមិក្តុលលើ ឃុំទ្រា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម ។

លោកម៉ាធូរ បូរិត អាយុ ៣៥ឆ្នាំ ជាអ្នកដឹកនាំក្រុមកម្មវិធីធំនៃអង្គការ Coup de Pouce Humanitaire ។ លោកធ្លាប់មកធ្វើការងារអ្នកស្ម័គ្រចិត្តនៅកំពង់ចាមកន្លងមក ។ លោកបានមានប្រសាសន៍ថា លោកបានពន្យល់បេសកកម្មរបស់លោកនិងស្ថានភាពសង្គមកម្ពុជា នៅអំឡុងពេលរយៈពេល ដែលលោកបានរស់នៅប្រទេសកម្ពុជា ប្រាប់ដល់យុវជនបារាំង ។ ក្រោយមកពួកគេក៏បានប្រាប់រូបលោកថា វាជាគំនិតល្អណាស់ ដែលជួយប្រជាជនខ្មែរក្រីក្រ ។ អ៊ីចឹងពួកគេក៏បានសម្រេចចិត្តជួយកសាងផ្ទះបីខ្នងដោយផ្ទាល់ដៃ ដល់បងប្អូនក្រីក្រនៅក្នុងព្រះសហ-គមន៍កាតូលិកភូមិនៅភាគកំពង់ចាមដែលអស់ទឹកប្រាក់សរុបចំនួន ៣០០០អឺរ៉ូ ។

គ្រីស្ទីនហាហ្សាត ជាអ្នកស្ម័គ្រចិត្តម្នាក់ក្នុងចំណោម ១៣នាក់ ក៏បានឱ្យដឹងថា : "ខ្ញុំមកទីនេះ ដើម្បីចែករំលែកជាមួយនិងបងប្អូននូវកម្លាំង ពេលវេលា និងភាពញញឹមរបស់ខ្ញុំ ព្រមទាំងរៀនពីប្រជាជននៅទីនេះផងដែរ" ។ ចំណែកឯកញ្ញា លូរ៉ង ឌី តាំងហ្គាយ អាយុ ២៤ឆ្នាំ បានបង្ហាញអារម្មណ៍ថា នាងរីករាយណាស់ដែលបានមកទីនេះ ។ នាងប្រាប់ខ្លួនឯងថា : "ខ្ញុំមិនចង់ចាកចេញពីទ្វីបអាស៊ី ដោយមិនបានទៅជួយប្រទេសក្រីក្រណាមួយនោះទេ" ។ ហើយឥឡូវនេះ នៅក្នុងភូមិក្តុលលើ វាអាចជាឱកាសល្អណាស់សម្រាប់នាងក្នុងការសម្រេចបំណង ។

អ្នកស្រីហាង សម្បត្តិ អាយុ៣៨ឆ្នាំ ជាកសិករ មានកូន៦នាក់ក្នុងបន្ទុក និងក៏ជាអ្នកមានឱកាសទទួលបានផ្ទះថ្មីមួយខ្នង មានប្រសាសន៍ថា ផ្ទះចាស់របស់អ្នកស្រីតូច និងមានភាពពិបាករស់នៅណាស់ដោយខូចធ្លុះធ្លាយជាច្រើនកន្លែង ។ "ខ្ញុំសូមអរគុណខ្លាំងណាស់ដល់យុវជនស្ម័គ្រចិត្តពីប្រទេសបារាំង ដែលបានមកជួយធ្វើផ្ទះថ្មីឱ្យខ្ញុំ" ។ អ្នកស្រីនិយាយដោយក្តីរំភើប ។ ចំណែកស្ត្រីចំណាស់ អាយុ ៦៤ឆ្នាំ ដែលមានឈ្មោះថាសែន ក៏បានទទួលផ្ទះមួយខ្នង ។ អ្នកស្រី ថ្លែងអំណរគុណចំពោះអង្គការបារាំង និងយុវ-ជនបារាំងទាំងអស់ ដែលបានមកជួយសាងសង់ផ្ទះថ្មីដល់គាត់នៅថ្ងៃនេះផងដែរ ។

ជាមួយទឹកភ្នែក និងសំឡេងអួលដើមករ អ្នកស្រីផល ម៉ាច បាននិយាយដែរថា : "ខ្ញុំរំភើបចិត្តណាស់ដែលឃើញយុវជនមកពីប្រទេសផ្សេងៗមកធ្វើផ្ទះឱ្យខ្ញុំ ។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលប្រទានអំណោយទានទាំងនេះឱ្យគ្រួសារខ្ញុំ" ។ ស្ត្រីរូបនេះក៏បន្ថែមថា នៅពេលមានផ្ទះថ្មីកូនរបស់គាត់នឹងមានកន្លែងរៀនស្រួល ហើយអ្នកស្រីនឹងខិតខំធ្វើការងារដើម្បីឱ្យកូនបានរៀនចប់ទាំងអស់គ្នា ។



## លោកបូជាចារ្យ អ៊ីវ៉ាន់ កំប៉ាញ៉ា សូមថ្លែងអំណរគុណ

ក្នុងនាមព្រះសហគមន៍កាតូលិកភូមិក្តុលលើ និងក្នុងនាមបងប្អូនគ្រួសារក្រីក្រទាំងអស់នៅក្នុងភូមិ លោកបូជាចារ្យអ៊ីវ៉ាន់ កំប៉ាញ៉ា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ "Coup de Pouce Humanitaire" ជាពិសេសចំពោះយុវជនស្ម័គ្រចិត្តបារាំងដែលបានចំណាយទាំងថវិកា ពេលវេលា កម្លាំងកាយ និងកម្លាំងស្មារតីដើម្បីមកជួយបងប្អូនយើងដែលក្រីក្រ។ នេះបានសបញ្ជាក់ឱ្យឃើញអំពីទឹកចិត្តមនុស្សធម៌ និងស្មារតីស្រឡាញ់រាប់អានរបស់ជនជាតិបារាំង ដែលមានចំពោះជនជាតិខ្មែរយើង។ មិនត្រឹមតែប៉ុណ្ណោះ សកម្មភាពទាំងនេះមានអត្ថន័យជាអនុស្សាវរីយ៍មិនអាចបំភ្លេចបានរបស់យុវជនបារាំងផងដែរ ដែលបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។



Photos: H. Soktheary

យុវជនស្ម័គ្រចិត្តបារាំងចុះជួយកសាងផ្ទះអ្នកក្រីក្រ

Mars-2008.qxd 3/24/2008 11:59 AM Page 8



# សកម្មភាពស្ម័គ្រចិត្ត ផ្តល់បទពិសោធន៍ដល់យុវជន

**ឡុង សម្ផស្ស**

នេះជាឱកាសមួយដ៏ល្អ ដែលយុវជន-នារីខ្មែរ អាចចូលរួមចំណែកនៅក្នុងសកម្មភាពស្ម័គ្រចិត្តជាមួយអង្គការ "យុវតាភាកម្ពុជា" ។ ពួកគេដែលទើបបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា (បរិញ្ញាបត្រ) ត្រូវបានទទួលការលើកទឹកចិត្តឱ្យបញ្ចេញនូវសមត្ថភាពខ្លួនក្នុងការជួយសហគមន៍ក្រីក្រតាមជនបទ ។

លោកជ្រិន សុធី មន្ត្រីផ្នែកទំនាក់ទំនងរបស់អង្គការយុវតាភាកម្ពុជាមានប្រសាសន៍ឱ្យដឹងថា: "អង្គការយុវតាភាកម្ពុជាបានបង្កើតឡើងនៅឆ្នាំ២០០៥ នៅក្រោមគំនិតផ្តួចផ្តើម នៃនាយិកាប្រតិបត្តិ បច្ចុប្បន្ន គឺលោកស្រីអេវ៉ាមី ស្លីវីក ។ នេះជាអង្គការឯករាជ្យ និងមិនមែនរដ្ឋាភិបាលនៅកម្ពុជា ដែលផ្តល់ឱកាសដល់យុវជនខ្មែរ អាចចូលរួមនឹងសេវាកម្មស្ម័គ្រចិត្ត រយៈពេល១ឆ្នាំ នៅតាមសហគមន៍ជនបទដែលនៅពុំទាន់មានការអភិវឌ្ឍន៍នៅឡើយ ។ អង្គការយុវតាភាកម្ពុជា ផ្តល់ឱ្យយុវជននូវដំណើរមួយដែលអាចផ្លាស់ប្តូរនូវខ្សែជីវិតរបស់ពួកគេ និងអភិវឌ្ឍខ្លួនពួកគេនូវជំនាញ ទំនុកចិត្ត និងឧត្តមគតិ ។



Photo : DR

យុវជនស្ម័គ្រចិត្តចុះទៅធ្វើការងារដល់មូលដ្ឋានប្រជាកសិករ

លោក សុធី បានឱ្យដឹងទៀតថា អង្គការមានគោលបំណងចង់បានសង្គមមួយ មានយុត្តិធម៌ និងសន្តិភាពតាមរយៈការបង្កើតឱ្យមានឡើងនូវសេវាកម្មពលរដ្ឋ មត្តុទ្ទេសភាពពលរដ្ឋនិងគោលគំនិតសហគ្រិនក្នុងសង្គម ។ យើងក៏បំពេញការងារដោយឈរលើជំនឿថា ដើម្បីកសាងសង្គមមួយ ដែលមាននូវយុត្តិធម៌ និងសន្តិភាពទៅបាន នោះគឺប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងការទទួលខុសត្រូវ ក្នុងការធ្វើវិភាគទានផ្សេងៗគ្នាសម្រាប់សង្គម ។

តាមការអង្កេតរបស់អង្គការយុវតាភា ក៏បានឱ្យដឹងថា ប្រជាជនខ្មែរមានអាយុនៅក្រោម ៣០ឆ្នាំ មានរហូតដល់៧០% ។ ដូច្នេះយើងឃើញថា យុវជនជាថាមពលដ៏សំខាន់មួយ ដែលអាចធ្វើឱ្យសង្គមមានការផ្លាស់ប្តូរបាន ។ ចំពោះលក្ខខណ្ឌដើម្បីធ្វើជាអ្នកស្ម័គ្រចិត្ត លោកសុធី បញ្ជាក់ថា: "ជានិស្សិតដែលបានបញ្ចប់ឧត្តមសិក្សា (បរិញ្ញាបត្រ) និងមានការតាំងចិត្តខ្ពស់ក្នុងការជួយសហគមន៍រយៈពេលពេញ ១ឆ្នាំ ។ ហើយយុវជនទាំងនោះ ត្រូវមានអាយុចាប់ពី ២០ ទៅដល់ ២៧ឆ្នាំ ។

អង្គការយុវតាភាកម្ពុជា ស្ថិតនៅបន្ទប់លេខ ១៣២ ជាន់ទី១ អគារភ្នំពេញ វិថីព្រះសុធារស នារាជធានីភ្នំពេញ ឬទូរស័ព្ទ: ០២៣ ២២៣១៧៣-៤ ។

## លាភ សុភាគុណ: "ការងារស្ម័គ្រចិត្តជួយខ្ញុំរីកចម្រើន"

កញ្ញាលាភ សុភាគុណ អាយុ ២១ឆ្នាំ ជានិស្សិតឆ្នាំទី៤ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកព័ត៌មានវិទ្យា ។ កញ្ញាមកពីក្រុងព្រះសីហនុ ជាកូនស្រីច្បងក្នុងចំណោមបងប្អូន៦នាក់ ។ តាំងពីឆ្នាំ២០០៤ មក កញ្ញាបានមករស់នៅក្នុង មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកដើម្បីបន្តការសិក្សា ។

ទាក់ទងនិងការងារស្ម័គ្រចិត្ត កញ្ញាលាភ សុភាគុណ បានចែករំលែកនូវបទពិសោធន៍ថា: "កាលពីរៀននៅឆ្នាំទី៣ ។ ខ្ញុំក៏ធ្លាប់ស្ម័គ្រចិត្តធ្វើការក្នុងក្រុមហ៊ុនឯកជនមួយអស់រយៈពេល៦ខែ ហើយការងារនេះជួយខ្ញុំឱ្យបានអនុវត្តជាក់ស្តែងនៅលើជំនាញដែលខ្ញុំបានរៀន ។ ទោះបីការងារនោះពុំបានប្រាក់កម្រៃក្តី ប៉ុន្តែក៏បានផ្តល់នូវបទពិសោធន៍ថ្មីសម្រាប់ខ្ញុំ ។ ខ្ញុំសង្កេតឃើញថា ការងារស្ម័គ្រចិត្ត មានប្រយោជន៍សម្រាប់ជីវិតខ្ញុំ ដែលពីមុន ខ្ញុំមិនមានបទពិសោធន៍ទាល់តែសោះ ប៉ុន្តែមួយរយៈក្រោយ ខ្ញុំមានការរីកចម្រើនទាំងសមត្ថភាព និងគំនិតបញ្ញា ។ តួយ៉ាងគឺដូចពេលខ្ញុំធ្វើការស្ម័គ្រចិត្តជាមួយក្រុមហ៊ុន គឺខ្ញុំមិនមែនតែរីកចម្រើន នៅលើមុខវិជ្ជាដែលខ្ញុំរៀននោះទេ តែវាបានជួយខ្ញុំឱ្យយល់ដឹងច្រើនលើផ្នែកផ្សេងទៀត ពោលគឺធ្វើឱ្យខ្ញុំទទួលបាន ជំនាញចម្រុះ បទពិសោធន៍ និងជំនាញទាំងការទំនាក់ទំនង និងបទពិសោធន៍ដទៃៗទៀតពីការងារនោះ ។



Photo : L. samphors

ឆ្លងកាត់បទពិសោធន៍ខាងលើមក នាំឱ្យកញ្ញាលាភ សុភាគុណបានទទួលនូវលទ្ធផលដ៏ល្អមួយ ។ ទោះបីនៅពេលនេះ កញ្ញាមិនទាន់បញ្ចប់ការសិក្សា ឆ្នាំទី៤ស្រួលបួលក្តី ក៏កញ្ញាបានដាក់ពាក្យ និងបានកំពុងធ្វើការងារជាមួយអង្គការអន្តជាតិមួយ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញនេះ ។







Photo : Ann-Laure Porré

ធារី ម៉ូលីណា មុំ

# ម្នាក់ៗតែងតែមាន មហិច្ឆតាផ្ទាល់ខ្លួន

**អាន ឡូរ៉ែ ប៉ូរ៉េ**

**ម៉ូលីណា អាយុ ២១ឆ្នាំ និស្សិតគ្រប់គ្រង និងគណនេយ្យ**

"អាយុពិតប្រាកដរបស់ខ្ញុំ គឺ១៩ឆ្នាំ ។ កាលពីខ្ញុំនៅតូច ខ្ញុំរំអុកម្តាយខ្ញុំចង់ទៅសាលារៀន ។ អ៊ីចឹងទើបម្តាយខ្ញុំកែថ្ងៃ ខែកំណើតខ្ញុំដើម្បីឱ្យខ្ញុំអាចចូលរៀនបានឆាប់រហ័ស ។ ពេលនោះ ខ្ញុំចង់ធ្វើគ្រូបង្រៀន ។ ហើយសព្វថ្ងៃ ខ្ញុំនៅតែប្រាថ្នាបង្រៀនសេដ្ឋកិច្ចនៅសកលវិទ្យាល័យ ដែលខ្ញុំអាចផ្តល់ឱ្យយុវជនជំនាន់ក្រោយនូវចំណេះដឹង ដែលមានសារៈប្រយោជន៍ ។ នេះ គឺជាមធ្យោបាយមួយនៅក្នុងការចូលរួមអភិវឌ្ឍប្រទេស ។ បញ្ហាទីមួយសម្រាប់ប្រទេសកម្ពុជា គឺធនធានមនុស្ស ។ ប្រសិនអ្នកមានចំណេះដឹង និងសមត្ថភាព នោះអ្នកវិនិយោគនឹងមក ។ ហើយអ្នកក៏នឹងកាន់តែខ្លាំងឡើងថែមទៀតដោយរៀនអំពីពួកគេ ។ ម្យ៉ាងទៀត ខ្ញុំចង់ធ្វើការនៅឯក្រសួងសេដ្ឋកិច្ចដែរដើម្បីជួយប្រទេសជាតិបន្តទៅទៀត ហើយនៅទន្ទឹមពេលគ្នានេះ ខ្ញុំអាចធ្វើការងារនៅអង្គការក្រៅរដ្ឋាភិបាលផងដែរ ។ ដើម្បីសម្រេចគោលដៅអស់ទាំងនេះ ខ្ញុំចង់បានអាហារូបករណ៍ ទៅសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសអាមេរិក ។ ដូច្នេះខ្ញុំត្រូវត្រៀមខ្លួនឱ្យបានល្អ ខិតខំរៀនសូត្រ ធ្វើយ៉ាងម៉េចឱ្យបានលទ្ធផលល្អ ។ ខ្ញុំមានសំណាង ដោយបានរស់នៅក្រុងភ្នំពេញ ជាកន្លែងដែលងាយស្រួល ក្នុងការរៀនសូត្រជាងនៅខេត្ត ។ ឪពុករបស់ខ្ញុំ គឺជាប៉ូលីស ចំណែកម្តាយរបស់ខ្ញុំមានអាហារដ្ឋានតូចមួយ ។ ពួកគាត់តែងលើកទឹកចិត្តខ្ញុំ ។ បើតាមគិត បន្ទាប់ពី២ឆ្នាំនៃការសិក្សាថ្នាក់អនុបណ្ឌិត ខ្ញុំនឹងត្រឡប់មកធ្វើការនៅស្រុកខ្មែរវិញ ហើយបន្ទាប់ពី២ឆ្នាំនៃបទពិសោធន៍វិជ្ជាជីវៈ ខ្ញុំបន្តសិក្សានៅថ្នាក់បណ្ឌិត" ។

**មុំ អាយុ ១៨ឆ្នាំ កូនជាងកាត់ដេរ**

"ឪពុកម្តាយរបស់ខ្ញុំរស់នៅចម្ងាយ១០០គមពីទីរួមខេត្តកំពង់ធំ ។ ពួកគាត់គឺធ្វើស្រែចំការ ។ ចំណែកខ្ញុំឈប់រៀន ២ឆ្នាំកន្លងមកហើយ គឺរៀនត្រឹមថ្នាក់ទី៨ ។ ហើយនៅឆ្នាំមុន ឪពុកម្តាយបានបញ្ជូនខ្ញុំ មកភ្នំពេញដើម្បីឱ្យខ្ញុំរៀនកាត់ដេរ ។ គាត់មិនចង់ឱ្យខ្ញុំក្លាយជាកសិករទេ ព្រោះវាគឺជាការងារនឿយហត់ពេក ។ ដូច្នេះខ្ញុំក៏បានមករៀនកាត់ដេរ ។ នៅពេលនេះ ខ្ញុំរកបាន ៦០០០០រៀល ក្នុងមួយខែៗ ប៉ុន្តែខ្ញុំនៅមានចំនុចជាច្រើនទៀត ដែលត្រូវរៀន ដូចជារៀនឱ្យចេះកាត់ក្រណាត់ឱ្យបានស្អាតជាដើម ។ នៅពេលដែលខ្ញុំពិភាក្សាជាមួយឪពុកម្តាយ ពីអនាគតខាងមុខ ខ្ញុំប្រាប់ពួកគាត់ថា ចំពោះខ្ញុំ ជាងកាត់ដេរ គឺជាការងារបណ្តោះអាសន្នប៉ុណ្ណោះ ។ ប្រសិនបើខ្ញុំអាចរកការងារបានផ្សេងពីនេះ ហើយរកប្រាក់បានច្រើនជាង វានឹងមានប្រយោជន៍ជាង ។ ទោះបីជាខ្ញុំបានរិះគិតច្រើនក៏ដោយ ប៉ុន្តែខ្ញុំលំបាកនឹងដឹងដែរពីអ្វីដែលខ្ញុំចូលចិត្ត និងធ្វើឱ្យខ្ញុំសប្បាយចិត្ត ។ ប៉ុន្តែខ្ញុំដឹងថា ប្រសិនបើខ្ញុំអាចស្វែងរកនូវការងារអ្វី ដែលខ្ញុំចូលចិត្ត គឺខ្ញុំនឹងខិតខំប្រឹងប្រែងគ្រប់កម្លាំងកាយចិត្ត ដើម្បីចាប់យកឱកាសនោះឱ្យបាន" ។

**ធារី អាយុ ២០ឆ្នាំ អ្នកត្បាញសូត្រ**

"ខ្ញុំរស់នៅជិតទីរួមខេត្តតាកែវ ខ្ញុំត្រូវបង្ខំចិត្តឈប់រៀន នៅថ្នាក់ទី៣ និងចាប់ផ្តើមធ្វើការនៅពេលខ្ញុំមានអាយុ១៨ឆ្នាំ ក្នុងខណៈនោះដែរ ខ្ញុំជួយម្តាយខ្ញុំមើលថែរក្សាប្អូន៧ខ្ញុំ ។ ក្នុងភូមិ ថៅកែសូត្រក៏បានចូលមក និងយកសរសៃសូត្រមកឱ្យយើងត្បាញ ។ គាត់វិលត្រឡប់មកទិញក្រណាត់សូត្រ ដែលយើងត្បាញ រួចគាត់លក់បន្តទៅទីក្រុងភ្នំពេញ ។ ខ្ញុំត្បាញក្រណាត់សូត្រជារៀងរាល់ថ្ងៃ ។ ខ្ញុំនៅមិនទាន់គិតពីអនាគតនៅឡើយទេ ដោយខ្ញុំមិនមានទាំងពេលវេលានឹងគិតផង ។ ខ្ញុំមានគម្រោងការដែរ ប៉ុន្តែខ្ញុំមិនដឹងថា នឹងអាចសម្រេចបានឬទេ? បច្ចុប្បន្ននេះ ខ្ញុំចាប់ផ្តើមរៀនជប៉ុននៅឯផ្ទះជាមួយនឹងលោកគ្រូម្នាក់ ។ តែគាត់ប្រហែលជានឹងឈប់បង្រៀនព្រោះមិនមានសិស្សមករៀនគ្រប់គ្រាន់ ។ តាមពិតខ្ញុំចង់ចេញទៅប្រទេសជប៉ុនដើម្បីស្វែងរកការងារធ្វើឱ្យដូចជាបងប្អូនជីដូនមួយរបស់ខ្ញុំ ដែលបានចាកចេញទៅធ្វើការនៅទីនោះយូរមកហើយ" ។

Mars-2008.qxd 3/24/2008 11:59 AM Page 10

## បទយកការណ៍

# បន្តិចម្តងៗ ស្ត្រីឈោងចាប់យកឱកាសការងារក្នុងសង្គម

**អាគីប**

ស្ត្រីកំពុងតែបានដើរតួនាទីយ៉ាងសំខាន់ទាំងនៅក្នុងសង្គម កន្លែងការងារ និងគ្រួសារ ។ នាបច្ចុប្បន្ននេះស្ត្រីបានឈានចូល ទៅក្នុងកិច្ចការងារសង្គម យ៉ាងច្រើនគួរឱ្យកត់សម្គាល់ ដោយពួកគេកំពុងចាប់យកការងារមួយចំនួន ដែលធ្លាប់តែត្រូវបានធ្វើ ដោយបុរស មានដូចជា សាស្ត្រាចារ្យ វេជ្ជបណ្ឌិត ប្រធានអង្គការ និងការងារនានាច្រើនទៀត ។ ពិតណាស់ ! ប៉ុន្មានឆ្នាំមកនេះ សកម្មភាពការងាររបស់ស្ត្រីហាក់មានសន្ទុះខ្លាំង ដោយខ្លះអាចមានលទ្ធភាពធ្វើការស្មើឬលើសបុរសមួយចំនួនផង ។ អ្នកខ្លះនិយាយថាស្ត្រីធ្វើការបានតែជាមួយនឹងចង្ក្រាន ចានឆ្នាំងទេ ពុំអាចមកអង្គុយក្នុងបន្ទប់ ឬធ្វើការងារល្អៗបានទេ ។ តើនេះជាការពិតឬ ? អ្នកស្រីចាន់ សំណាង ជាចៅសង្កាត់ឬស្សីកែវ មានប្រសាសន៍ថា : "ច្បាស់ណាស់ស្ត្រីមិនអាចធ្វើការងារដូចបុរសមែន ប៉ុន្តែទស្សនៈនេះ បានរលាយបាត់ពីផ្នត់គំនិតរបស់ស្ត្រីខ្មែររួចទៅហើយ" ។ អ្នកស្រីបន្តទៀតថា បើយើងនិយាយថាស្ត្រីអាចធ្វើការដូចបុរសបាននោះ នឹងមានបុរសខ្លះស៊កសំដីបកមកវិញថា អ៊ីចឹង ឱ្យស្ត្រីទៅលីបាវ ឬក៏ធ្វើការងារធ្ងន់ៗឱ្យដូចបុរសទៅ ។ ប៉ុន្តែស្ត្រីៗ ដែលអាចធ្វើការងារដូចបុរសនេះ មិនមែនសំដៅទៅលើភាសាបែបនេះទេ គឺសំដៅទៅលើគោលការណ៍ដឹកនាំ ដូចដែលយើងឃើញ មានស្ត្រីមួយចំនួនក្លាយជាអ្នកដឹកនាំប្រទេស ឬអង្គភាពណាមួយជាដើម ។

ជាមួយនេះផងដែរ កញ្ញាគង់ ករុណា ដែលបានចូលប្រឡូកក្នុងការងារជាអ្នកគ្រប់គ្រងប្រព័ន្ធវិបសាយនៅសមាគម ចៅវ៉ាអាត អស់រយៈពេលជិត ២ឆ្នាំមកហើយនោះ ក៏បានទទួលស្គាល់ថា ការងារដែលនាងកំពុងកាន់កាប់សព្វថ្ងៃនេះ ជាការងារសម្រាប់បុរសភាគច្រើន ។ ប៉ុន្តែការងារមិនដែលប្រកាន់ថាប្រុស ឬស្រីនោះទេឱ្យតែអ្នកនោះ អាចធ្វើបានទៅតាមលទ្ធភាព និងសមត្ថភាពរបស់គេ ។

**គោលបំណងខុសៗគ្នា**

មនុស្សម្នាក់ៗតែងប្រាថ្នាចង់ធ្វើអ្វីមួយ ឬចង់ក្លាយជាមនុស្សមួយរូប ដែលល្បីនៅក្នុងសង្គមតាំងពីតូច ដោយគ្រាន់តែអ្នកខ្លះអាចសម្រេចបំណង និងអ្នកខ្លះ មិនអាចសម្រេចបានប៉ុណ្ណោះ ។ អ្នកគ្រូណើ ចិន្តា ជាសាស្ត្រាចារ្យ ផ្នែកបដិសណ្ឋារកិច្ចសណ្ឋាគារ និងទេសចរណ៍ សាលាប៉ូល ឌុយប្រុយ ខេត្តសៀមរាប ហាក់មានមោទនភាពខ្លួនឯង ដែលបានក្លាយខ្លួនជាសាស្ត្រាចារ្យមួយរូប ដោយនាងពុំដែលបានត្រៀមលក្ខណៈទុកជាមុនផង ។ ចិន្តាក៏បានប្រាប់ថា : "វាមិនមែនជាការងារដែលខ្ញុំប៉ងប្រាថ្នាពីតូចនោះទេ ។ វាគឺគ្រាន់តែជាការងារមួយ ដែលឆ្លើយតបទៅនឹងចំណេះដឹងដែលខ្ញុំបានរៀននៅមហាវិទ្យាល័យតែប៉ុណ្ណោះ" ។ នាងក៏បន្ថែមទៀតផងដែរថា នាងមិនដឹងថា នឹងចាប់យកអាជីពអ្វីនៅពេលអនាគតនោះទេជាពិសេសការងារដែលនាងស្រលាញ់ ដូចពិបាកបន្តិច ។ ផ្អាកសំដីមួយភ្លែត ហាក់ដូចនៅក្នុងសភាពកំពុងនឹករឿងអ្វីមួយ នាងបន្តទៀតថា នាងនឹងធ្វើការងារណាមួយ ឬចាប់យកការងារថ្មី គឺលុះត្រាតែការងារនោះមានការទាក់ទងគ្នានឹងអ្វីដែលនាងបានរៀន ។ ប៉ុន្តែប្រសិនបើការងារសព្វថ្ងៃ អាចឱ្យនាងបង្កើននូវសមត្ថភាពខ្ពស់ថែមទៀត នាងគឺនៅតែធ្វើរហូត ។ "បើថាស្ត្រីកំពុងដណ្តើមការងារបុរសនោះ ខ្ញុំសុំប្រឆាំងគំនិតនេះពីព្រោះយើងម្នាក់ៗធ្វើការដើម្បីជីវភាព និងតាមសមត្ថភាពរៀងខ្លួន មិនអាស្រ័យទៅលើភេទនោះទេ ។" នាងបន្ថែម ។

ងាកមកអ្នកនាងម៉េង សុមនាវិញ ដែលកំពុងបម្រើការងារជាអ្នកទទួលខុសត្រូវក្រុមសៀវភៅ "ខ្ញុំចង់អាន" ប្រចាំនៅអង្គការស៊ីប៉ា បានបញ្ចេញចំណាប់អារម្មណ៍ផងដែរថា បំណងរបស់នាង គឺមិនប្រាកដច្បាស់ថាធ្វើអ្វីមួយទេ ។ តែអ្វីដែលសំខាន់សម្រាប់នាង ដើម្បីជ្រើសរើសយកនូវការងារណាមួយនោះ គឺឱ្យតែការងារដែលទាក់ទងសៀវភៅ គឺនាងពេញចិត្តទាំងអស់ ។ "វាមិនមែនជាក្តីប៉ងប្រាថ្នាខ្ញុំពីតូចនោះទេ ប៉ុន្តែខ្ញុំចូលចិត្តការងារនេះពីព្រោះខ្ញុំធ្វើការជាមួយសៀវភៅ ។ ខ្ញុំចូលចិត្តសៀវភៅ" ។ សុមនាមិនប្រាកដ និងមិនកំណត់គោលដៅថាធ្វើអ្វីមួយឱ្យច្បាស់នោះ គឺមិនមានទេ ។ កាលនៅពីតូចនាងចង់ធ្វើជាអ្នកការទូត តែនៅពេលធំឡើងបំណងនេះបានប្រែក្លាយជាចង់ធ្វើគ្រូបង្រៀនវិញ តែអ្វីដែលនាងបានគិតទុក ត្រូវបានរលាយអស់ ។ ចំណែកឯឪពុកម្តាយនាងចង់ឱ្យធ្វើជាគ្រូពេទ្យ ។ ទឹកមុខលាយនឹងសំឡេងសើចបន្តិច សុមនាក៏បន្ថែមថា ឪពុកម្តាយរបស់នាងពុំមានការប្រឆាំងនឹងនាងទេ ដោយគ្រាន់តែគាត់មានការអាក់អន់ចិត្តបន្តិច ។

**តើយុវជន-នារីឆ្លើយតបទៅនឹងបំណងឪពុកម្តាយ ?**

ឪពុកម្តាយគ្រប់ៗរូប តែងតែប្រាថ្នា ចង់ឱ្យកូនមានការងារល្អសម្រាប់អនាគតរបស់ពួកគេ ហើយក្នុងនោះមានអាណាព្យាបាលខ្លះបានជ្រើសរើស ឬអាចកំណត់ការងារឱ្យកូនតែម្តង បើទោះបីពួកគេពុំចង់ក៏ដោយ ។ អាណាព្យាបាលទាំងនោះ អាចសម្រេចសម្រេចបំណងរបស់ខ្លួនបានឬទេ ?

កញ្ញាអ៊ុង ច័ន្ទសោភា ជាអ្នកយកព័ត៌មានកាសែតបារាំងកំបូដស័រ ។ ដោយការបរាជ័យក្នុងការក្លាយជាមេធាវីដែលជាបំណងពីតូចរបស់នាង នាងបានចាប់យកជំនាញជាអ្នកសារព័ត៌មាន ម្យ៉ាងគឺដោយសារនាងស្រលាញ់ការសរសេរ ហើយការងារនេះក៏មិនសូវឃើញមានមនុស្សស្រីធ្វើ ។ សោភានិយាយថា : "ឪពុកម្តាយខ្ញុំក៏បានប្រឆាំងនឹងអ្វីដែលខ្ញុំកំពុងធ្វើនេះ ព្រោះវាជាការងារដែលប្រឈមនឹងគ្រោះថ្នាក់ច្រើន ។ ម្យ៉ាងទៀតគាត់គិតថា វាគឺជាការងារសម្រាប់បុរស មិនស័ក្តិសមសម្រាប់មនុស្សស្រី ធ្វើទេ" ។ ដើមឡើយ នាងយល់ស្របនឹងគំនិតនេះដែរ ប៉ុន្តែក្រោយពីនាងបានប្រឡូក ជាមួយការងារនេះមួយរយៈមក វាមិនមានបញ្ហាសម្រាប់នាង ហើយនាងក៏អាចធ្វើបានដូចបុរសដែរ ។

ដូចគ្នានេះ អ្នកគ្រូចិន្តាក៏ពុំបានបំពេញតម្រូវការនៃឪពុកម្តាយនាងដែរ ។ អ្នកគ្រូបានប្រាប់ថា : "ឪពុកម្តាយខ្ញុំមានគម្រោងឱ្យធ្វើជាគ្រូពេទ្យ ប៉ុន្តែការចង់បានរបស់ពួកគាត់ត្រូវបានអាក់ខាន ពីព្រោះ ខ្ញុំមិនអាចបំពេញបំណងរបស់ពួកគាត់បាន ។" ចិន្តាបានចាប់យកការងារផ្នែកបដិសណ្ឋារកិច្ចនេះជាង ៣ឆ្នាំមកហើយ ហើយនាងមិនទាន់អាចនិយាយបានថា នេះគឺជាការងារនាពេលអនាគតរបស់នាងដែរ បើការងារនេះអាចបង្កើននូវសមត្ថភាពខ្ពស់ និងផលប្រយោជន៍ច្រើន នាងនឹងធ្វើរហូត ។ ចំពោះបញ្ហានេះដែរ លោកសុផល ជាចៅកែឡានដឹកដី បានឱ្យដឹងថា : "ខ្ញុំចង់ឱ្យកូនក្លាយជាគ្រូពេទ្យ ប៉ុន្តែកូនខ្ញុំក៏មិនចូលចិត្តការងារដែលខ្ញុំចង់ឱ្យវាធ្វើទេ គឺគេទៅរៀនផ្នែកធនាគារវិញ" ។ លោកបន្តទៀតថា លោកមិនអាចតម្រូវតាមចិត្តរបស់ខ្លួនឯងបានទេពីព្រោះវាអាស្រ័យលើការចូលចិត្តរបស់កូនផងដែរ ។

**ស្ត្រីកំពុងចាប់យកអាជីពបុរស**

កញ្ញាធរ សុវណ្ណ ពុំទាន់ច្បាស់ខ្លួនឯងទេថា ការងារដែលនាងកំពុងធ្វើនេះជាការងារអនាគតរបស់នាងនោះ ។ សុវណ្ណជាមគ្គុទ្ទេសក៍ និងជាអ្នកលក់នៅក្នុងក្រុមហ៊ុនអាទីហ្វែនមួយនៅខេត្តសៀមរាប ក៏បានឱ្យដឹងថា : "ការងារនេះខ្ញុំស្រលាញ់ ប៉ុន្តែខ្ញុំនឹងមិនធ្វើរហូតទេ ។ ខ្ញុំនឹងប្តូរការងារថ្មី ឬអាចទៅបន្តការសិក្សានៅប្រទេសបារាំងបន្ថែម ។" ជាមួយនេះដែរ កញ្ញាច័ន្ទសោភា មិនចាប់យកការងារនេះរហូតដែរ ដោយនាងនឹងផ្លាស់ប្តូរទៅធ្វើជាអ្នកដឹកនាំ ឬនិពន្ធនាយករងនៅតាមស្ថាប័នឬតាមអង្គការនានា ប៉ុន្តែស្ថិតនៅក្នុងជំនាញសារព័ត៌មានដដែល ។ នាងក៏បន្តដោយហាក់មានការភ្ញាក់ផ្អើលថា ការដែលស្ត្រីអាចធ្វើការងារបាន ដូចបុរសនោះ មិនមែនក្នុងន័យជាការប្រកួតប្រជែងអ្វីជាមួយបុរសនោះទេ គ្រាន់តែអាចនិយាយបានថា មនុស្សស្រី ពិតប្រាកដជាមានសមត្ថភាព ឬលទ្ធភាពអាចធ្វើបានដូចបុរស ពោលគឺ "បុរសធ្វើបាន យើងក៏អាចធ្វើបានដែរ" ។

អ្នកស្រីអ៊ុំ ចាន់ថន ដែលក្លាយខ្លួនជាអ្នករត់ម៉ូតូឌុបអស់ពេលជាង ៧ឆ្នាំមកហើយនោះ ក៏ពុំទទួលយកការងារនេះជារៀងរហូតដែរ ។ អ្នកស្រីនិយាយថា: "ការងារនេះពិបាកណាស់សម្រាប់ខ្ញុំ ដូច្នេះខ្ញុំមិនចង់ធ្វើវាជារៀងរហូតទេ ។ ខ្ញុំនឹងរកមុខរបរថ្មីនៅពេលខ្ញុំចាស់ជាងនេះ ។" អ៊ីចឹងតើការងារណាមួយ គឺជាការងាររបស់ស្ត្រីពិតប្រាកដនោះ ?








Photos : S. Philong, P. Samphy

### ទិវានារីអន្តរជាតិមានប្រភពមកពីណា ?

**នៅថ្ងៃទី៨ មីនា ឆ្នាំ១៨៩៩ កម្មការិនីផ្នែកតម្បាញ និងកាត់ដេរនៅទីក្រុងស៊ីកាហ្គោ និងទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក បានរួបរួមសាមគ្គីគ្នា ហើយក្រោកឈរតស៊ូយ៉ាងប្តូរផ្តាច់ដើម្បីទាមទារឱ្យបន្ថយម៉ោងធ្វើការ និងដំឡើងប្រាក់បៀវត្សរ៍។ ទោះបីមានការចាប់ធ្វើទារុណកម្មយ៉ាងណាក្តី ពួកគេនៅតែសាមគ្គីគ្នាយ៉ាងជិតស្និទ្ធតស៊ូប្រឆាំងជាសាធារណៈម្តងហើយម្តងទៀតក្នុងគោលបំណងបង្ខំឱ្យពួកម្ចាស់រោងចក្រ និងពួកនាយទុនយល់ព្រមតាមការទាមទាររបស់ពួកគេ។ ក្រោយមកនៅឆ្នាំ១៩១០ មានការរៀបចំសន្និបាតអន្តរជាតិនារី ដែលមានប្រទេស១៧ចូលរួម។ សន្និបាតត្រូវបានធ្វើឡើងនៅទីក្រុងកូប៉ែនហាគែន ប្រទេសដាណឺម៉ាក និងបានសម្រេចយកថ្ងៃ៨មីនា ថាជាថ្ងៃប្រារព្ធ "ទិវានារីអន្តរជាតិ" ដែលជានិមិត្តរូបនៃថ្ងៃមហាសាមគ្គី និងការតស៊ូរបស់នារីពលករទូទាំងពិភពលោកដើម្បីសិទ្ធិសេរីភាព។**

### ចំនួនស្ត្រីធ្វើការដូចបុរស

**របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី បង្ហាញថា ស្ត្រីខ្មែរតិចបំផុតមិនដល់ ១០ %ផង ក្នុងចំនួនស្ត្រីដ៏ច្រើនសន្ធឹកសន្ធាប់ ដែលកំពុងបំពេញការងារគ្រប់ក្រសួងមន្ទីរស្ថាប័នរដ្ឋាភិបាលសាធារណៈនានា។ ក្រោយពីការបោះឆ្នោតអាណត្តិទី៣ ឆ្នាំ២០០៤ កន្លងមក ស្ត្រីដែលមានតួនាទីនៅក្នុងព្រឹទ្ធសភា មានចំនួនប្រហែល ១០ % ក្នុងចំណោមព្រឹទ្ធសមាជិក ៦១នាក់។ ស្ត្រីក្នុងរដ្ឋសភាវិញ មានចំនួន ២០ % ក្នុងចំណោមតំណាងរាស្ត្រ ១២៣នាក់។ ស្ត្រីដែលមានតួនាទីនៅក្នុងឃុំ មានមិនដល់ ១០ % ទេ នៅក្នុងចំណោមមន្ត្រីឃុំជាង១ម៉ឺននាក់។ រីឯស្ត្រីជារដ្ឋមន្ត្រីវិញ មានចំនួនតិចតួចប៉ុណ្ណោះ ក្នុងចំណោមរដ្ឋមន្ត្រី ២៥នាក់។ ចំណែកស្ត្រីជាចៅហ្វាយខេត្ត គឺមិនមានម្នាក់ទាល់តែសោះ។ ជាមួយនេះដែរសម្តេចអគ្គសេនាបតីតេជោហ៊ុន សែន បានកំពុងគាំទ្រឱ្យមានការលើកកម្ពស់ការងារនារី ដោយឱ្យមានការផ្តល់តំណែងឱ្យស្ត្រីអាចធ្វើជាចៅហ្វាយស្រុក និងចៅហ្វាយខេត្តរងផងដែរ។**

Mars-2008.qxd 3/24/2008 11:59 AM Page 12

# កសិកម្ម

## ដាំស្ពៃចង្កឹះ យ៉ាងណាបានលទ្ធផលល្អ?

**ទស្សនាវដ្តី កសិករ លេខ ៩៤**


Photos: L. Samphors

ស្ពៃជាដំណាំមួយប្រភេទ ដែលកសិករខ្មែរនិយមដាំជាលក្ខណៈគ្រួសារ ។

**ការរៀបចំដីសាប និងការសាប**

ថ្នាលសាបគ្រាប់ ត្រូវកាប់បំផុសដីហាល ៣ថ្ងៃ (ដីសើម) និងដីស្ងួត ហាល ១ថ្ងៃ បន្ទាប់មក លើករងដែលមានទទឹង ០,៨ម និងបណ្ដោយ ៥ម ។ ដាក់ដីកំប៉ុស្ដ ៥បង្គី លាយដីបាតត្រពាំង ៤បង្គី ក្នុង១រង ។ បន្ទាប់ពីរៀបចំថ្នាលរួច ត្រូវស្រោចទឹកលើថ្នាលឱ្យជោក ទើបយកគ្រាប់មកសាបស្ដើងៗ ហើយរកដីមានជីវជាតិមករោយពីលើស្ដើងៗ ថែមទៀត ។

**ការរៀបចំដីស្ទូង និងការស្ទូងកូន**

ពេលកូនស្ពៃអាយុ១០-១៣ថ្ងៃ ទើបដកយកទៅស្ទូងលើរង ។ រងស្ទូងកូន ត្រូវដាក់ជី ធ្វើដូចរងសាបកូនដែរដោយច្របល់ដីឱ្យសព្វ បន្ទាប់មកក៏ស្រោចទឹកឱ្យជោក ទើបយកកូនស្ពៃមកស្ទូង ។ ដកកូនស្ពៃដែលមានដើមថ្លោសៗល្អ យកទៅស្ទូង ដោយទុកចន្លោះពីគុម្ព១ ទៅគុម្ព ១ មាន ប្រវែង ១តឹកកន្លះ និងចន្លោះរង កន្លះតឹក ។ ការស្ទូងកូនធ្វើពេលល្ងាច ព្រោះ អាចធ្វើឱ្យការស្រូបសំណើមបានល្អ និងជួយសម្រួលឱ្យកូនដំណាំ មានភាពស៊ាំបានយូរ ។

**ការថែទាំ**

ក្រោយពីស្ទូងហើយរយៈពេលមួយសប្ដាហ៍ ស្រោចទឹកជីកំប៉ុស្ដម្ដង ។ ក្នុងជីកំប៉ុស្ដទឹក ១លីត្រ គឺលាយទឹកធម្មតា១០លីត្រ ។ បន្ទាប់ពីស្រោចទឹកជីបាន ៣ថ្ងៃ ត្រូវតែចាប់ផ្ដើមបោចស្មៅជ្រោយដី និងយកជីកំប៉ុស្ដ ទៅរោយពីលើបន្ថែមទៀត តាមចន្លោះគុម្ពស្ពៃដើម្បីជួយជំរុញការដុះលូតលាស់ ។ ការស្រោចទឹកជីនេះ គឺធ្វើឡើងរយៈពេល ៧ថ្ងៃម្ដង ដោយធ្វើរបៀបនេះរហូតដល់ពេលជិតប្រមូលផល ។

**ការធ្វើជីកំប៉ុស្ដទឹក**

ត្រូវមានស្លឹកឈើស្រស់១៥គ.ក លាមកសត្វស្រស់ ១០គ.ក និងទឹក៥០លីត្រ ។ ត្រូវយកស្លឹកឈើនោះទៅចិញ្ច្រាំឱ្យល្អិតរួចយកទៅច្របល់ជាមួយលាមកសត្វឱ្យសព្វ ទើបដាក់ចូលទៅក្នុងពាង បន្ទាប់មកគឺចាក់ទឹកចូលចំណុះ ៥០លីត្រ កូរវាឱ្យសព្វ រួចគ្របទុកក្រោមម្លប់ឈើ ។ យើងត្រូវតែរក្សាទុកល្បាយនោះ ក្នុងរយៈពេលពី២៥ ទៅ៣០ថ្ងៃ ប៉ុន្តែត្រូវកូរវាមួយថ្ងៃម្ដង ដើម្បីឱ្យជីឆាប់រលួយ ។ នៅពេលធ្វើការស្រោចលើដំណាំ ត្រូវយកទឹកជី១លីត្រ លាយជាមួយទឹកធម្មតា ១៥លីត្រ ស្រោចរាល់ ៣ថ្ងៃម្ដង និងត្រូវស្រោចពេលល្ងាចត្រជាក់លុះដល់ពេលព្រឹកត្រូវស្រោចទឹកធម្មតាលាងវាឱ្យបានស្អាតវិញ ។

**បរិស្ថាន**

### ចង្ក្រានពន្លឺព្រះអាទិត្យ

វាជាឧបករណ៍មួយ ដែលយើងអាចចំអិនអាហារដោយគ្រាន់តែប្រើកម្ដៅព្រះអាទិត្យ គឺមិនចាំបាច់ប្រើឆ្នាំងអគ្គិសនី ឬអុសដែលទាមទារឱ្យចំណាយថវិកាច្រើន និងបំពុលបរិស្ថានទៀតផង ។ ចង្ក្រានព្រះអាទិត្យផ្អែកលើកន្លែងរស់នៅដែលសម្បូរទៅដោយពន្លឺថ្ងៃ និងទម្លាប់ចម្អិនម្ហូបអាហារ ។ ប្រជាជននៅឯប្រទេសមួយចំនួន ដែលប្រើប្រាស់ចង្ក្រានប្រភេទនេះ គឺអាចជួយឱ្យគេចំណេញពេលវេលាថវិកា ថែមទាំងផ្ដល់សុខភាពល្អផងដែរ ។ សម្រាប់អាហារ គេអាចចំអិនតាមប្រភេទចង្ក្រាននីមួយៗ ។ ចង្ក្រានដែលមានសីតុណ្ហភាពទាប អាចចំអិនអាហារសន្សឹមៗ ពុំបង្ហំ នៅពេលចំអិនបាយ ឬសម្រាប់ម្ហូបអាហារស្ងោរ អាំង-ល- ។ ចំណែកចង្ក្រានព្រះអាទិត្យដែលមានសីតុណ្ហភាពខ្ពស់វិញ សម្រាប់អាហារពេលចៀន ឆា ឬដុតជាដើម ។


Photo: DR

ចង្ក្រានព្រះអាទិត្យ គឺកំពុងតែពេញនិយមសម្រាប់មនុស្សជាច្រើន ដើម្បីចម្អិនអាហារប្រចាំថ្ងៃ ។ វាការពារធម្មជាតិ និងបរិស្ថានពិភពលោកផងដែរ ។ ចង្ក្រានព្រះអាទិត្យ បានបង្កើតឡើងដោយអង្គការអន្តរជាតិចង្ក្រានព្រះអាទិត្យ ដែលមានទីតាំងនៅសង្កាត់សាក្រាមិនតូ រដ្ឋកាលីហ្វ័រញ៉ា នៅសហរដ្ឋអាម៉េរិក និងនៅឯប្រទេសកេនយ៉ា ។ ចង្ក្រានព្រះអាទិត្យត្រូវបានរកឃើញ នៅឆ្នាំ១៩៨៧ ។ រហូតមកដលពេលបច្ចុប្បន្ននេះ មានប្រមាណ៣០០០០គ្រួសារទទួលបាននូវអត្ថប្រយោជន៍ ដោយផ្ទាល់ពីចង្ក្រានព្រះអាទិត្យនៅជុំវិញពិភពលោក ។

**ប្រែសម្រួលដោយថុង យ៉ត**



# សុខភាព

## ត្រៀមខ្លួនក្នុងការរួមភេទលើកដំបូង

**ឡុង សម្ផស្ស**



សុខភាពបន្តពូជមានសារៈសំខាន់ខ្លាំងណាស់ ដែលមនុស្សគ្រប់ៗរូបត្រូវយកចិត្តទុកដាក់ ។

**តើដៃគូស្នេហាគួរត្រៀមខ្លួនដូចម្ដេចសម្រាប់ការរួមភេទលើកដំបូង ?**

ទាក់ទងទៅនឹងបញ្ហានេះ លោកស្រី ស៊ុ គីមហៀក អនុប្រធានផ្នែកកាមរោគ និងសម្ភពនៃមន្ទីរពេទ្យបង្អែកសម្ដេចឪ ដែលស្ថិតនៅក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ នៅរាជធានីភ្នំពេញ ក៏មានប្រសាសន៍ ប្រាប់ឱ្យដឹងថា : "បើនិយាយអំពីអាយុសម្រាប់ដៃគូទាំងពីរ ដែលអាចរួមភេទបាននោះ គឺបើចំពោះស្ត្រីភេទ នាងត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង ។ នៅក្នុងវ័យនេះ នាងមានលក្ខណៈរូបកាយសម្បទានគ្រប់គ្រាន់សម្រាប់ទទួលយកការមានផ្ទៃពោះបាន ។ ដោយឡែកចំពោះបុរសវិញ ត្រូវមានអាយុចាប់ពី ២៣ឆ្នាំឡើង ដែលពួកគេអាចមាននូវទំនួលខុសត្រូវចំពោះទាំងសុខភាព និងបញ្ហាសេដ្ឋកិច្ចក្នុងគ្រួសារ ។ ប៉ុន្តែសម្រាប់បុរសនេះ យកល្អគួរតែរង់ចាំរៀបចំខ្លួនឯង ឱ្យមានភាពរឹងមាំ លើផ្នែកសេដ្ឋកិច្ចជាមុនសិនទើបប្រសើរ ។

លោកស្រីបានសង្កត់ធ្ងន់ថា : "បើគិតពីអនាគត នៃគូស្រករទាំងពីរ ពួកគេត្រូវទៅធ្វើការពិនិត្យឈាមជាចាំបាច់សិនមុនពេលរៀបការ ។ ហើយក្រោយពីទទួលបានលទ្ធផលអវិជ្ជមានពីមេរោគអេដស៍ និងមេរោគឆ្លងផ្សេងៗ នោះភាគីទាំងពីរអាចរៀបការបាន ។ បើធ្វើបានដូច្នេះ ទើបក្រោយពេលរៀបការក្លាយទៅជាប្ដីប្រពន្ធហើយ ការរួមភេទលើកដំបូងរបស់ដៃគូទាំងពីរ អាចប្រព្រឹត្តទៅបានយ៉ាងរលូន និងប្រកបដោយសុវត្ថិភាព ។

ការសម្អាតខ្លួនប្រាណមុន និងក្រោយពេលរួមភេទជារឿងសំខាន់ ហើយចាំបាច់បំផុតចំពោះសុខភាពបន្តពូជរបស់គូស្វាមីភរិយា ។ តាមពិតជំងឺកាមរោគមួយចំនួនតែងបានកើតឡើង នៅពេលដែលពួកគេប្រព្រឹត្តការរួមភេទដោយខ្វះអនាម័យ ។ ទោះបីជាយ៉ាងណា ប្រសិនបើពួកគេជួបប្រទះបញ្ហា និងជំងឺឆ្លងទាំងអស់នេះ ពួកគេអាចទៅស្វែងរកសេវានៃការព្យាបាលជំងឺឆ្លងទាំងនោះពីគ្រូពេទ្យជំនាញ ។ សម្រាប់ការព្យាបាលជំងឺកាមរោគ អ្នកជំងឺត្រូវមកទទួលនូវការព្យាបាល ទាំងប្ដី-ប្រពន្ធ ឬដៃគូស្នេហ៍របស់ពួកគេតែម្ដង ហើយនៅអំឡុងពេលទទួលនូវព្យាបាលដៃគូត្រូវតមការរួមភេទជាចាំបាច់ គឺរហូតដល់ការព្យាបាល បានជាសះស្បើយ ១០០% ។

### ២៣៥៨៧នាក់ ទទួលថ្នាំពន្យាជីវិត

ក្នុងចំណោមអ្នកដែលបានឆ្លងរោគអេដស៍ទាំងអស់ មាន២៣៥៨៧នាក់ បានទទួលការព្យាបាលដោយថ្នាំពន្យាជីវិត។ ហើយជិតពាក់កណ្ដាលនៃអ្នកឆ្លងថ្មីៗ គឺជាស្ត្រីដែលទទួលការចម្លងពីស្វាមីរបស់ពួកគាត់ និងមួយភាគបីនៃករណីចម្លងថ្មីៗ គឺឆ្លងពីម្ដាយដែលមានផ្ទុកមេរោគអេដស៍ទៅកាន់កូន។ នៅឆ្នាំ២០០៣ គេប៉ាន់ប្រមាណថា មានកុមារ ៥៥ ០០០នាក់ ក្លាយជាក្មេងកំព្រាដោយសារជំងឺអេដស៍។ ជំងឺអេដស៍ជាបញ្ហាចម្បងក្នុងសង្គម ថ្មីៗនេះ អង្គការស៊ីដ (ការចែករំលែកបទពិសោធន៍ដើម្បីសម្របទៅតាមការអភិវឌ្ឍន៍) បានបង្កើតទស្សនាវដ្ដីមួយហៅថា "រួបរួមគ្នា" ដែលមានអត្ថបទអប់រំ និងណែនាំដល់អ្នកផ្ទុក និងមានជំងឺអេដស៍។ ទស្សនាវដ្ដីនេះចែកជូនមិនគិតប្រាក់នៅតាមមណ្ឌលផ្ដល់ថ្នាំពន្យាជីវិត។ សូមប្រិយមិត្តរកមើលកុំបីខាន។ ទំនាក់ទំនងព័ត៌មានតាមទូរស័ព្ទ : ០១២ ២២៣ ០៩០។

## តើគ្រួសក្នុងប្រម៉ាត់ជាអ្វី?


Photo: P. Samphy

លោកវេជ្ជបណ្ឌិតឡឹម តារា ឯកទេសវះកាត់នៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ពេទ្យរុស្ស៊ី) មានប្រសាសន៍ថា ជំងឺគ្រួសក្នុងប្រម៉ាត់ជាការកើតមាននូវវត្ថុរឹងមួយ ឬច្រើន នៅក្នុងប្រព័ន្ធទឹកប្រម៉ាត់ គឺក្នុងថង់ទឹកប្រម៉ាត់ ឬផ្លូវបង្ហូរទឹកប្រម៉ាត់ ។

ជំងឺនេះបណ្ដាលមកពីមានការប្រែប្រួលនៃភាគ-រយរបស់ធាតុផ្សំ នៅក្នុងប្រម៉ាត់ ។ ចំណែកនៅក្នុងប្រទេសកម្ពុជាភាគច្រើន គឺបណ្ដាលមកពីការកើតមានព្រូននៅក្នុងពោះវៀន ។ ម្យ៉ាងទៀតការនិយមបរិភោគអាហារដែលមានជាតិខ្លាញ់ខ្លាំងពេក ក៏នាំឱ្យមានកើតគ្រួសដែរ ។ កត្តាមួយទៀតគឺគ្រួសក្នុងប្រម៉ាត់បណ្ដាលមកពីចលនាបង្ហូរទឹកប្រម៉ាត់ដើម្បីចូលរួមរំលាយអាហារមានសភាពរអាក់រអួល ដើរមិនស្រួល ធ្វើឱ្យទឹកប្រម៉ាត់កករកើតជាគ្រួស ។

ជំងឺគ្រួសក្នុងប្រម៉ាត់នេះ ៧០% មិនមានរោគសញ្ញាអ្វីទាំងអស់ ។ ប៉ុន្តែបើវាមានរោគសញ្ញា គឺអ្នកជំងឺច្រើនមានការឈឺចាប់ ផ្នែកខាងក្រោមឆ្អឹងជំនីខាងស្ដាំ ឈឺនៅចុងដង្ហើម ឬឈឺជារលក ឈឺឡើងខ្លាំងមែនទែនរួចស្រកមកវិញ ។ បើមានបែបនេះ គឺអ្នកជំងឺត្រូវទៅរកគ្រូពេទ្យជំនាញ ដើម្បីធ្វើការវិនិច្ឆ័យរោគ និងធ្វើការព្យាបាល ព្រោះរោគសញ្ញារបៀបនេះក៏កើតមានលើប្រភេទជំងឺជាច្រើនទៀតដែរ ។

ការព្យាបាល ជំងឺគ្រួសក្នុងប្រម៉ាត់ គឺត្រូវធ្វើការវះកាត់ យកថង់ទឹកប្រម៉ាត់ចេញតែម្ដង ពីព្រោះទោះមិនមាន ប្រម៉ាត់ក៏យើងអាចរស់ ក្នុងសភាពធម្មតាបានដែរ ។ ដូច្នេះដើម្បីជួយបង្កា កុំឱ្យមានជំងឺគ្រួសក្នុងប្រម៉ាត់ យើងត្រូវមានអនាម័យចំណីអាហារ កុំឱ្យកើតមានជំងឺព្រូន កុំបរិភោគចំណីអាហារដែលមានជាតិខ្លាញ់ ច្រើនពេក និងត្រូវយកចិត្តទុកដាក់ក្នុងការថែទាំសុខភាពឱ្យបានមែនទែន ។

Mars-2008.qxd 3/24/2008 12:00 PM Page 14

# ប្រពៃណី



Photo : S. Philong

# ស្វែងយល់អំពីរបាំគោះត្រឡោករបស់ខ្មែរ

**អាគីប**

គោះត្រឡោក គឺជារបាំប្រពៃណីនៃប្រជាជនខ្មែរ ដែលរស់នៅឯភាគខាងត្បូង ឆៀងខាងកើតនៃប្រទេសកម្ពុជា គឺនៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀង។

របាំនេះ គឺបានប្រសូតចេញពីទំនៀមទម្លាប់របស់អ្នកស្រុក ដែលនិយមដាំដូង និងប្រើប្រាស់ដូង ជាប្រយោជន៍ច្រើនយ៉ាង តាំងពីឫស ដើម ធាង ស្លឹក ផ្លែ ទឹក ឬសាច់ រហូតដល់លលាដ៏ដូងផងដែរ។ ប្រជាជនរស់នៅតាមស្រុកស្រែ-ចំការ បានយកលលាដ៏ដូងនេះ មកធ្វើជាឧបករណ៏ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាធ្វើវែក យកធ្វើត្រឡោកដួសទឹក ហើយច្នៃធ្វើជាឧបករណ៏តន្ត្រីដូចជាទ្រអ៊ូជាដើម។ លលាដ៏ដូង គឺជាត្រឡោកដែលគេយកមកគោះ សម្តែងក្នុងរបាំនេះឯង។ លលាដ៏ដូងនេះ គេអាចគោះទង្គិចគ្នា បង្កើតជាសំឡេង បានយ៉ាងពីរោះដែលជាហេតុនាំឱ្យការគោះត្រឡោកក្លាយជាទម្លាប់លេងត្រាប់តាមក្បាច់ផ្សេងៗ។

កាលពីឆ្នាំ១៩៦០ ក្រុមប្រជុំទំនៀមទម្លាប់ប្រពៃណីអ្នកស្រុកបានធ្វើស្រាវជ្រាវសិក្សាជ្រើសមកច្នៃរបាំគោះត្រឡោកនេះឡើង។ ម្យ៉ាងទៀត នេះគឺជាការបកស្រាយបង្ហាញចំណងទាក់ទងក្នុងមនោសញ្ចេតនាបេះដូងដ៏បរិសុទ្ធ ដែលជាប្រពៃណីល្អរវាងកម្លោះ-ក្រមុំនៅស្រុកភូមិផងដែរ។ ត្រឡោកគឺជាតំណាងដល់ស្រី និងប្រុស ទឹក និងដី ដែលវាមានប្រវត្តិជាប់ទាក់ទងទៅនឹងប្រពៃណីទំនៀមទម្លាប់នៃអាពាហ៏ពិពាហ៏ដែលមានជាយូរយាណាស់មកហើយនៅក្នុងប្រវត្តិ-សាស្ត្រនៃប្រទេសកម្ពុជា។ របាំនេះនិយមលេងក្នុងពិធីផ្សេងៗ ដូចជា ក្នុងពិធីមង្គលការ និងហែកូនកម្លោះជាដើម។

**សម្លៀកបំពាក់វាំរបាំ**

ចំពោះនារីស្លៀកសំពត់ចងក្បិនពណ៌បៃតង (ផាមួង) ពាក់អាវចាប់រាងឡេវពីក្រោយខ្នងកមូល ដៃវែងត្រ័រកា នៅត្រឹមកំភួនដៃ (ក្រោមគួយដៃបន្តិចពណ៌ផ្ទៃមេឃ) មានចងពង់ពីលើអាវដោយគួចធ្វើជារាងផ្កានៅពីលើដើមទ្រូងខាងឆ្វេង បញ្ចេញចុងជាយកន្សែងខាងស្តាំបន្តិច ហើយទើបក្រវ៉ាត់ខ្សែក្រវ៉ាត់ពីលើចង្កេះសំពត់ និងកន្សែង។ នៅលើសក់ មានសៀតផ្កាពណ៌ស ក្រហម ឬក៏លឿងនៅខាងឆ្វេងក្បាល។ ចំណែកបុរសបុរសពាក់អាវសន្ទះពណ៌កំបោរ (ជាលឿងចាស់) ស្លៀកសំពត់ចងក្បិន គឺពណ៌ឈាមជ្រូកពីលើអាវសន្ទះ រួចក្រវ៉ាត់នូវក្រណាត់ពណ៌លឿង (ពណ៌កំបោរ) នៅពីលើចង្កេះសំពត់ដោយទុកជាយទម្លាក់ខាងឆ្វេង។

## អំណាន

### សារ៉ាម៉ានី



សារ៉ាម៉ានី ជារឿងប្រលោមលោកមួយដ៏ពិសិដ្ឋ ដែលបាននិពន្ធដោយលោករ៉ូឡង់ ម៉ឺយែរ។ ប្រលោមលោកនេះបានបកប្រែជាភាសាខ្មែរ និងបោះពុម្ពផ្សាយនាឆ្នាំ១៩៧១ ដោយអ្នកស្រីចន្ទបូផល។ ក្នុងស្នាដៃដ៏កម្រនេះ អ្នកនិពន្ធរៀបរាប់ អំពីជីវប្រវត្តិរបស់សារ៉ាម៉ានី ដែលនាងកា វ័យក្មេងម្នាក់ និងបានចូលរស់នៅក្នុងព្រះបរមរាជវាំង តាំងពី៨ឆ្នាំ។ សារ៉ាម៉ានីនាំអ្នកអានឱ្យស្គាល់អំពីជីវភាពពិតនៅក្នុងរាជវាំង អំពីជីវភាពរបស់រាស្ត្រសាមញ្ញ និងអំពីសង្គមខ្មែរនារជ្ជកាលព្រះបាទស៊ីសុវត្ថិ(១៩០៤-១៩២៧) ដែលជាសម័យកាលមួយដែលប្រទេសខ្មែរយើងស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ។

ជីវភាពនៅក្នុងរាជវាំង! យើងប្រាកដជាស្រមៃទៅដល់ទីស្ថានដ៏រុងរឿង វិមានស្កឹមស្កៃ កម្រាលព្រំល្អៗ ព្រះមហា-ក្សត្រដែលមានប្រាជ្ញាគ្មានផ្ទឹម... តែនរណាម្នាក់នឹកស្មានថារាជវាំងជាទីកន្លែងច្របូកច្របល់រកស្មានមិនដល់នោះ? ប្រលោមលោកនេះលក់ក្នុងតំលៃ ៦៨០០រៀល។

### ជីវិតកូនថ្លៃ កូនត្រូវតែរស់



"ជីវិតកូនថ្លៃ កូនត្រូវតែរស់ទៀត" គឺជាសំដីចុងក្រោយរបស់ឪពុក មុនស្លាប់ ផ្តាំទៅកូនប្រុស ដែលកំពុងត្រដររស់យ៉ាងលំបាកបំផុត។ បើគ្មានបណ្តាំនេះទេ ប្រហែល លោកពិនយ៉ាថៃ ដែលជាអ្នកនិពន្ធសក្ខី-ភាពនេះ មិនអាចរស់រានមានជីវិត គេចផុតពីក្រញ៉ាំរបបខ្មែរក្រហមបានឡើយ។ ស្នាដៃនេះបានបោះពុម្ពដំបូង ជាភាសាអង់គ្លេស បន្ទាប់មក គឺមានភាសាបារាំង អាឡឺម៉ង់ ហូឡង់ ហ្វីលីពីន និងថៃជាដើម ហើយនៅក្នុងឆ្នាំ២០០៣ ទើបមានការចេញផ្សាយជាភាសាខ្មែរ។

នាខែមេសា ឆ្នាំ១៩៧៥ លោកពិន យ៉ាថៃ និងគ្រួសារត្រូវជន្លៀសចេញពីក្រុងភ្នំពេញ។ លោកបានហែលទារុណកម្មការអត់ឃ្លាន ជំងឺរ៉ាំរ៉ៃ ការងារធ្ងន់ធ្ងរ និងសេចក្តីភ័យខ្លាចគ្រប់ពេលវេលា។ ក្នុងឆ្នាំ១៩៧៧ លោកសម្រេចចិត្តរត់ជាមួយភរិយាឆ្លងកាត់ជួរភ្នំក្រវ៉ាញទៅប្រទេសថៃ។ លោកបានរស់នៅក្នុងវិប្បដិសារី ពីព្រោះលោកមិនអាចយកកូនប្រុសសំលាញ់ចិត្ត ដែលឈឺមកតាមជាមួយលោកបាន។ រឿងដ៏រញ្ជួយចិត្តនេះ ត្រូវបានចងក្រងឡើង ទុកជាសក្ខី-ភាពប្រវត្តិសាស្ត្រនាសម័យកាលមួយ ដ៏ជូរចត់របស់ខ្មែរ។ រឿងនេះលក់ក្នុងតំលៃ ១៧០០០រៀល។

**សុជាតា**



# ប្រវត្តិសាស្ត្រ

# ស៊ីរី លង្កា ក្នុងប្រវត្តិដ៏រំជើបរំជួល




Photo : DR

**អាន ឡូរ៉ឺ ប៉ូរ៉េ**

ប្រទេសស៊ីរី លង្កា ពីដើម មានឈ្មោះថា សីឡង់។ ឆ្នេរសមុទ្រប្រទេសនេះ ទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយរលកយក្សស៊ូណាមី កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៤។ ប្រវត្តិសាស្ត្រ របស់ប្រទេសនេះ បានបង្ហាញឱ្យឃើញនូវព្រឹត្តិការណ៏រំជើបរំជួលនានា តាមរយៈទីតាំងភូមិសាស្ត្រ។ ប្រទេសស៊ីរីលង្កា គឺមានទីតាំងស្ថិតនៅជិតឆ្នេរសមុទ្រប្រទេសឥណ្ឌា ដែលវាធ្វើឱ្យជនជាតិតាមិុលអាចមកតាំងទីលំនៅបានយ៉ាងឆាប់រហ័ស។

ព្រះពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញដែនកោះ។ នៅសតវត្សទី៦ ប្រទេសស៊ីរីលង្កា បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជាណាចក្រ ដ៏ល្បីល្បាញ នៃប្រទេសឥណ្ឌាខាងត្បូង គឺព្រះរាជា-ណាចក្រចូឡា។ ហើយដោយសារតែការទាញយកអត្ថប្រយោជន៏អំពីវិស័យជំនួញ សម័យបុរាណ ជនជាតិអារ៉ាប់ដែលតែងតែធ្វើដំណើរឆ្លងកាត់ទៅមករវាងសមុទ្រម៉េឌីទែរ៉ានេ និងមហាសមុទ្រឥណ្ឌា ក៏មានវត្តមានជាប្រជាជនដែលកាន់សាសនាឥស្លាមនៅលើកោះស៊ីរីលង្កា។ អ្នកមកគ្រប់គ្រងដែនកោះបន្ទាប់ មានជនជាតិព័រទុយហ្គាល់។ ដោយមានការចាប់អារម្មណ៏នឹងជំនួញគ្រឿងទេស ពួកគេបានមកដាក់អាណានិគម នៅលើប្រទេសស៊ីរី លង្កា នៅឆ្នាំ១៥០៥ ហើយក៏ព្យាយាមប្រែក្លាយប្រជាជនលើដីកោះ ឱ្យទៅជាគ្រីស្តសាសនិកកាតូលិក។ សតវត្សទី១៧ ដល់វេនជនជាតិហូឡង់មកគ្រប់គ្រងជំនួសម្តង ហើយដែលត្រូវបណ្តេញចេញ ជាបន្ទាប់ដោយជនជាតិអង់គ្លេស។ ជនជាតិអង់គ្លេសមិនសប្បាយចិត្តប៉ុន្មានទេ សម្រាប់ការគ្រប់គ្រងដែនកោះនេះ។ ពួកគេបានរៀបចំរដ្ឋបាល គ្រប់គ្រងពិតប្រាកដមួយ កសាងផ្លូវថ្នល់ ផ្លូវដែក និងអភិវឌ្ឍវប្បធម៌តែ។ ក៏ដូចជាប្រទេសផ្សេងៗទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងពីពួកបស្ចិមប្រទេស នៅដើមសតវត្សទី២០ ចលនាដើម្បីឯករាជ្យភាពបានកើតចេញ ជាសំឡេងប្រឆាំងនឹងអាណានិគម ត្រូវបានគេរៀបចំឡើងនៅប្រទេសស៊ីរីលង្កា។ ដូច្នេះក្រុងឡុងដ៏ បានយល់ព្រមប្រគល់នូវទម្រង់ស្វ័យភាព ឱ្យដល់ដែនកោះនៅឆ្នាំ១៩៤៨ (ប៉ុន្តែឯករាជ្យពិតប្រាកដ ត្រូវបានប្រកាសឡើងនៅឆ្នាំ១៩៧២ ដែលវាគឺជាកាលបរិច្ឆេទដែលដែនដីកោះនេះបានដូរឈ្មោះរបស់ខ្លួនផងដែរ)។ របបគ្រប់គ្រងតាមបែបសភា ត្រូវបានបង្កើតឡើង។ អ៊ីចឹងក្នុងជីវភាពនយោបាយ គឺត្រូវបានគ្រប់គ្រងដោយការឆ្លាស់វេនគ្នារវាងគណបក្សកំណែទម្រង់ និងគណបក្សអភិរក្ស។ ដំណាក់កាលដំបូង ក្រុមអភិរក្សបានដឹកនាំជីវភាពនយោបាយ។ បន្ទាប់មកពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៧៧ ក្រុមកំណែទម្រង់បានដឹកនាំរដ្ឋាភិបាលម្តង។ ប៉ុន្តែពួកគេបានបរាជ័យនៅឆ្នាំ១៩៩៤។ ទោះជាយ៉ាងណា ពួកគេបានបន្សល់ទុកអនុស្សាវរីយ៏ជាប្រវត្តិសាស្ត្រ ដោយបានដាក់ស្ត្រីឱ្យធ្វើជានាយករដ្ឋមន្ត្រីដំបូងគេនៅលើពិភពលោកនៅឆ្នាំ១៩៦០។

គ្រប់គណបក្សនយោបាយកាន់អំណាចទាំងអស់ គឺបានទទួលការឈឺចាប់ ជាមួយនិងលំបាកខាងផ្នែកសេដ្ឋកិច្ច កំណើនអ្នកគ្មានការងារធ្វើ ចំនួនប្រជា-ជន និងរឿងអំពើពុករលួយ-ល-។ គណបក្សកាន់អំណាច ក៏មិនមានលទ្ធភាព នឹងដោះស្រាយសំណុំរឿងក្រុមបំបែកខ្លួនខ្លាតាមិុល ដែលមានការគាំទ្រដោយអន្តរាគមន៏របស់ប្រទេសឥណ្ឌា ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩០ផងដែរ។ ដូច្នេះមហន្តរាយគឺនៅតែមាន ជនរងគ្រោះពីជម្លោះកើនឡើងឥតឈប់ឈរ ដែលរាប់ទៅប្រមាណជា ១០.០០០ប្លាយ នាក់។

### តើក្រុមឧទ្ទាមខ្លាតាមិុលជានរណា?

**ជនជាតិតាមិុលភាគច្រើនរស់នៅភាគខាងជើងនៃកោះស៊ីរី លង្កា មានភាសាផ្ទាល់ខ្លួន និងប្រតិបត្តិហិណ្ឌូសាសនា។ ចាប់តាំងពីទសវត្សរ៏ទី៥០ សិនហ្គាឡេបានក្លាយជាភាសាផ្លូវការ ហើយសាសនាព្រះពុទ្ធក្លាយជាសាសនារដ្ឋ។ គណបក្សនៃក្រុមជនជាតិតាមិុលស្នើសុំបង្កើតរដ្ឋដាច់ឡែក និងមានស្វ័យភាពផ្ទាល់ខ្លួនដែលធ្វើឱ្យប្រឈមមុខជាមួយជនជាតិសិនហ្គាឡេ។ ស្ថានភាពនេះបង្កឱ្យមានអំពើហិង្សាម្តងហើយ ម្តងទៀតនៅក្នុងទសវត្សរ៏ឆ្នាំ១៩៧០ និងឆ្នាំ១៩៨០ និងរហូតមកទល់នឹងពេលថ្មីៗនេះ។ ក្រុមខ្លារំដោះ អ៊ីឡេមតាមិុលដែលទទួលមូលនិធិពីការជួញដូរជាលក្ខណៈអន្តរជាតិ ត្រូវបានគេស្គាល់ដោយសារក្រុមនេះបានប្រើការវាយប្រហារអត្តឃាត និងជាក្រុមតំណាងឱ្យចលនាបំបែកខ្លួន។ អាក្រក់ជាងនេះ រាល់ការប៉ុនប៉ងធ្វើការសម្រុះសម្រួលប៉ុន្មានឆ្នាំចុងក្រោយនេះពីសំណាក់ប្រទេសណ័រវេសតែងតែត្រូវបរាជ័យជារហូត។**

# ល្បែងកំសាន្ត

## ពាក្យខ្មែរ

សូមប្អូនៗ ភ្ជាប់រូបឡានដឹកទំនិញទៅនឹងស្រមោលរបស់វានីមួយៗ។ ហើយជួយរកផង នូវស្រមោលឡានមួយ ដែលសល់តែឯងនោះ។




## ផាត់ពណ៌

ករុណាចង់ផាត់ពណ៌ តែនាងមិនដឹងផាត់ពណ៌អ្វី ឱ្យត្រូវនឹងរូបនីមួយៗទេ។
សូមប្អូនៗជួយករុណាផាត់ពណ៌ឱ្យបានត្រឹមត្រូវផង។



## ការងារប្រចាំខែ

- ថ្ងៃទី១៦ មីនា : បុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូនៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) ដោយមានរៀបចំអភិបូជាពេលព្រឹក និងមានពិធីហែស្លឹក។
- ថ្ងៃទី២០ មីនា : ព្រះយេស៊ូតាំងអគ្គសញ្ញាព្រះកាយ និងព្រះលោហិត។ ម៉ោង ៣:០០ រសៀល មានរៀបចំពិធីលើកលែងទោស នៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច)។
- ថ្ងៃទី២១ មីនា : ព្រះសហគមន៍សន្តយ៉ូសែប រៀបចំពិធីគោរពព្រះយេស៊ូរងទុក្ខលំបាក និងសោយទិវង្គត។ នៅម៉ោង៨:០០ ព្រឹក ដើរផ្លូវព្រះឈើឆ្កាង និងម៉ោង ៣:០០ រសៀល ពិធីលើកលែងទោស (ផ្ទាល់ខ្លួន) ចំណែកម៉ោង ៦:៣០ ល្ងាច មានអធិដ្ឋានតេហ្សេ។
- ថ្ងៃទី២២ មីនា : រាត្រីបុណ្យចម្លង។
- ថ្ងៃទី២២ មីនា : ក្នុងឱកាសបុណ្យចម្លង ព្រះសហគមន៍ក្រុងព្រះសីហនុ មានរៀបចំពិធីថ្វាយអភិបូជាធំមួយដែលមានបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករមកពីព្រះសហគមន៍ផ្សេងៗក្នុងក្រុងព្រះសីហនុ។
- ក្នុងឱកាសបុណ្យចម្លង : ព្រះសហគមន៍ក្រុងព្រះសីហនុ មានអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកចំនួន ១៩នាក់ ដែលជាកូនគ្រីស្តបរិស័ទមកពីព្រះសហគមន៍ផ្សេងៗ នៅក្នុងក្រុងព្រះសីហនុ និងខេត្តកោះកុង។
- ក្នុងឱកាសបុណ្យចម្លងនេះដែរ : អ្នកស្វែងយល់ចំនួន២០នាក់ មកពីព្រះសហគមន៍កំពង់គោ កំពង់រទេះ ព្រែកស្បូវ និងភូមិប៉ាងនៃភូមិភាគបាត់ដំបង បានទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះសហគមន៍ខេត្តកំពង់ធំនៃភូមិភាគបាត់ដំបង។
- ថ្ងៃទី២៤ មីនា : ពិធីបញ្ចុះបឋមសិលាវិទ្យាស្ថានបច្ចេកទេសសន្តហ្វ្រង់ស្វ័រនៅភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អ្នកឧកញ៉ាបណ្ឌិតចាន់ សារុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ថ្ងៃទី៥-៨ មេសា : សិក្ខាសាលាគ្រូអប់រំបន្តជំនឿទាំងបីភូមិភាគនៅព្រះសហគមន៍កាតូលិកចំការទៀង នៅឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។
- ថ្ងៃទី៩ មេសា : ចែកអំណោយដល់គ្រួសារក្រីក្រចំនួន ១០០គ្រួសារ នៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) ម៉ោង ៩ ព្រឹក។